

ស៊ីកាដា
cicada

# ឧស្សាហកម្មវប្បធម៌ និង ច្នៃប្រតិដ្ឋក្រៅប្រព័ន្ធ នៅកម្ពុជា៖

# ការកំណត់ធនធានមនុស្ស និងស្ថានភាពសេដ្ឋកិច្ចសង្គម

ដោយ៖
យ៉ុង សុខភា
សាយ តុលា
ម៉េត មន្ទារី

## សេចក្តីថ្លែងអំណរគុណ

គម្រោងស្រាវជ្រាវនេះ អាចដំណើរការទៅបានដោយសារមានការចូលរួមគាំទ្រពីអ្នកពាក់ព័ន្ធនានា។ ក្រុមការងារស្រាវជ្រាវរបស់សមាគមស៊ីកាដា សូមថ្លែងអំណរគុណចំពោះសិល្បករ និងប្រតិបត្តិកររប្បធម៌ទាំងអស់ ដែលបានចំណាយពេលវេលាផ្ទាល់ខ្លួន ដើម្បីចូលរួមឆ្លើយតបទៅនឹងកម្រងសំណួរតាមអនឡាញ និងតាមការចូលរួមផ្តល់បទសម្ភាសដោយផ្ទាល់។ យើងខ្ញុំក៏សូមសម្តែងនូវការដឹងគុណដល់អ្នកសម្របសម្រួល និងប្រធានក្រុមនៅតាមបណ្តាខេត្តនានា ដែលរួមមាន៖ ខេត្តកំពត សៀមរាប បាត់ដំបង កំពង់ធំ និងភ្នំពេញ ដែលបានជួយសម្រួលដល់ដំណើរការសម្ភាសន៍ផ្ទាល់មាត់នៅតាមបណ្តាខេត្តរបស់ខ្លួន។ យើងខ្ញុំក៏មិនអាចបំភ្លេចបាននូវគុណបំណាច់របស់មន្ទីររប្បធម៌ និងវិចិត្រសិល្បៈទាំងអស់ ក៏ដូចជា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលបានជួយជ្រោមជ្រែងកិច្ចការស្រាវជ្រាវរបស់យើងខ្ញុំ និងជួយផ្តល់បញ្ជីឈ្មោះសិល្បករ និងប្រតិបត្តិកររប្បធម៌នៅតាមបណ្តាខេត្តក្រុងខាងលើ។

គម្រោងស្រាវជ្រាវនេះទទួលបានការឧបត្ថម្ភមូលនិធិពី មូលនិធិអន្តរជាតិដើម្បីភាពផ្សេងៗគ្នានៃវប្បធម៌ ហៅកាត់ថា “IFCD” របស់អង្គការយូណេស្កូ។

## អំពីសមាគមស៊ីកាដា

សមាគមដើម្បីការអភិវឌ្ឍ និងការគាំទ្រឧស្សាហកម្មកៃច្នៃនៃកម្ពុជា (សមាគមស៊ីកាដា) គឺជាសមាគមដែលទើបតែបានចុះបញ្ជីថ្មីៗនេះ ដើម្បីធ្វើជាតំណាងឱ្យវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋនិងវប្បធម៌នៅកម្ពុជា។ សមាគមនេះត្រូវបានបង្កើតឡើងក្រោមការឧបត្ថម្ភមូលនិធិពី មូលនិធិអន្តរជាតិដើម្បីភាពផ្សេងៗគ្នានៃវប្បធម៌ ហៅកាត់ថា "IFCD" របស់អង្គការយូណេស្កូ ហើយដំណើរការកម្មវិធីរបស់សមាគមវិញ គឺទទួលបានការឧបត្ថម្ភហិរញ្ញវត្ថុពីអង្គការសិល្បៈខ្មែរអមតៈ ហៅកាត់ថា «សខអ» ។ អង្គការសិល្បៈខ្មែរអមតៈ បានប្រតិបត្តិការការងាររបស់ខ្លួនតាំងពីឆ្នាំ ១៩៩៨ ដើម្បីជួយជ្រោមជ្រែងដល់ការអភិវឌ្ឍវិស័យសិល្បៈ តាមរយៈការផ្តល់ការបណ្តុះបណ្តាល, មូលនិធិ និងធនធានផ្សេងៗ និងតាមរយៈការផលិតកម្មវិធីនិងមហោស្រព និងដឹកនាំគម្រោងយុទ្ធសាស្ត្រផ្សេងៗ។

សមាគមស៊ីកាដា បានបង្កើតឡើងដោយតំណាងអង្គការវប្បធម៌ចំនួន ៦រូប ដែលបានមើលឃើញពីតម្រូវការឱ្យមានសម្ព័ន្ធភាពក្នុងផ្នែកឧស្សាហកម្មនេះ ដើម្បីតស៊ូមតិលើបញ្ហារួមនានា ដោយរាប់បញ្ចូលទាំងសិទ្ធិអ្នកនិពន្ធ, សេរីភាពសិល្បៈ, ក្របខណ្ឌពន្ធដារ និងហិរញ្ញវត្ថុជាដើម។ ក្នុងឆ្នាំ ២០២២-២០២៣ សមាគមស៊ីកាដា បានដឹកនាំគម្រោងស្រាវជ្រាវមួយ ដោយកំណត់ធនធានមនុស្សក្នុងវិស័យវប្បធម៌ក្រៅប្រព័ន្ធ និងកំពុងបន្តដំណើរការកម្មវិធីបណ្តុះបណ្តាលកម្មវិធីតស៊ូមតិមួយដែលមានឈ្មោះថា ***អាហារូបករណ៍អភិវឌ្ឍវិញ្ញត្តិវប្បធម៌***។ សមាគមក៏បានរៀបចំជំនួបបបមមួយជាមួយសិល្បករ និងប្រតិបត្តិករវប្បធម៌ដើម្បីប្រឹក្សា និងឈ្វេងយល់អំពីអទិភាពរបស់ពួកគេ។ សមាគមនេះស្ថិតក្រោមការដឹកនាំដោយគណៈកម្មការនាយកឯករាជ្យមួយ។

សមាគមស៊ីកាដា មានគោលដៅ ៖

- ពង្រឹងទំនាក់ទំនង និងជំរុញឱ្យមានកិច្ចសហការរវាងវិស័យឯកជន និងសាធារណៈ ដើម្បីធ្វើឱ្យវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋនិងវប្បធម៌កាន់តែមានការទទួលស្គាល់ និងចូលរួមនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច នយោបាយ និងសង្គម។
- ស្រាវជ្រាវ អភិវឌ្ឍ និងស្វែងរកការគាំទ្រ តាមរយៈកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ ដើម្បីបង្កើតឱ្យមានរចនាសម្ព័ន្ធមួយប្រកបដោយនិរន្តរភាព និងបរិយាបន្ន សម្រាប់វិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌។
- បង្កើន និងផ្សព្វផ្សាយការងារដែលមានវិជ្ជាជីវៈពិតប្រាកដនៃសមាជិករបស់ខ្លួន តាមរយៈការផ្លាស់ប្តូរចំណេះដឹង និងការប្រតិបត្តិល្អ។

សមាគមស៊ីកាដានឹងបង្កើតវគ្គសិក្ខាសាលាណែនាំមួយ ស្តីពីគោលនយោបាយវប្បធម៌ និងណែនាំអ្នកធ្វើការក្នុងវិស័យវប្បធម៌ ឱ្យស្គាល់អំពីសិទ្ធិរបស់ពួកគេដូចជាកម្មសិទ្ធិបញ្ញា, សេរីភាពបញ្ចេញមតិ និងការចុះបញ្ជីផ្នែកច្បាប់។ សមាគមស៊ីកាដា នឹងបង្កើតឱកាសដើម្បីអាចទទួលបានព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ តាមរយៈការផ្តល់ជាព័ត៌មានសង្ខេបអំពីគោលនយោបាយវប្បធម៌រៀងរាល់ពីរខែម្តង និងរបាយការណ៍តាមដានទិន្នន័យប្រចាំពីរឆ្នាំម្តង ដោយចែករំលែកព័ត៌មានអំពីស្ថានភាពបច្ចុប្បន្ន និន្នាការ និងការអភិវឌ្ឍផ្នែកច្បាប់នៅក្នុងវិស័យមួយនេះ។ តាមរយៈសន្និបាតប្រចាំឆ្នាំរបស់ខ្លួន សមាគមស៊ីកាដា នឹងធ្វើជាអ្នកតំណាងវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ ដែលហ៊ាននិយាយឈរលើភស្តុតាងជាក់ស្តែង ទាក់ទងនឹងរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជន ដោយមានការចូលរួមជាសំឡេងពីសមាជិករបស់ខ្លួនជាចំណេះ ជំនាញ និងការលើកទឹកចិត្ត ដើម្បីជាកម្លាំងជំរុញដល់ការចូលរួមបែបប្រជាធិបតេយ្យ គណនេយ្យភាព និងតម្លាភាព។

# សេចក្តីសង្ខេប

របាយការណ៍នេះ មានបំណងឈ្វេងយល់អំពីទិដ្ឋភាពនៅក្នុងវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ក្រៅប្រព័ន្ធនៅកម្ពុជា ដោយសិក្សាអំពីស្ថានភាពប្រជាសាស្ត្រ, ជំនាញ និងការអប់រំ, លក្ខខណ្ឌការងារ, របៀបរបបនៃការរស់នៅ ព្រមទាំងអាជីពនិងភាពប្រឈមរបស់សិល្បករ និងអ្នកធ្វើការក្នុងឧស្សាហកម្មវប្បធម៌ក្រៅប្រព័ន្ធ ដែលបានកំណត់ថាជាអ្នកធ្វើការឯករាជ្យ បុគ្គលស្វ័យនិយោជន៍ អ្នកស្ម័គ្រចិត្ត អ្នកធ្វើការមិនពេញម៉ោង ម្ចាស់សហគ្រាសក្រៅផ្លូវការ និងអ្នករកស៊ីលក្ខណៈគ្រួសារ។ ការសិក្សាស្រាវជ្រាវបានធ្វើឡើងតាមវិធីពីររបៀបដោយប្រើប្រាស់កម្រងសំណួរក្នុងទម្រង់អនឡាញ និងដោយការសម្ភាសផ្ទាល់ ជាមួយសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ចំនួន ៤១៤ នាក់ ដែលមកពីតំបន់ផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា និងបានសម្ភាសលម្អិតបន្ថែមជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗចំនួន ៧ នាក់ ដែលបានចូលរួមនៅក្នុងការស្ទង់មតិនេះ ដើម្បីយល់កាន់តែស៊ីជម្រៅអំពីក្តីបារម្ភ ភាពប្រឈម និងការរំពឹងទុករបស់ពួកគាត់។

ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ក្រៅប្រព័ន្ធភាគច្រើន គឺជាបុរស រីឯស្ត្រីវិញ ទំនងជាឆាប់បោះបង់អាជីពជាង ដោយសារអាពាហ៍ពិពាហ៍ ការងារផ្ទះសម្បែង និងការមើលថែទាំកូន។ លទ្ធផលក៏បង្ហាញឱ្យឃើញដែរថា សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌មួយចំនួនមានពិការភាព។ សិល្បករ និងប្រតិបត្តិករវប្បធម៌ភាគច្រើនរស់នៅ និងធ្វើការនៅក្នុងតំបន់សេដ្ឋកិច្ចសំខាន់ៗ តួយ៉ាងដូចជា ភ្នំពេញ បាត់ដំបង និងសៀមរាប។ ដើម្បីធ្វើការនៅក្នុងវិស័យវប្បធម៌ និងឧស្សាហកម្មច្នៃប្រតិដ្ឋ សិល្បករ និងប្រតិបត្តិករវប្បធម៌ មិនចាំបាច់មានសញ្ញាបត្រសាកលវិទ្យាល័យឡើយ ដោយពួកគេគ្រាន់តែរៀនជំនាញពីការបណ្តុះបណ្តាលក្រៅប្រព័ន្ធ។ ដ្បិតតែសិល្បករ និងប្រតិបត្តិករវប្បធម៌ចេះជំនាញច្រើនក្នុងវិស័យឧស្សាហកម្មវប្បធម៌ ភាគច្រើន ពួកគាត់ចេះជំនាញឯកទេសខាងតន្ត្រី និងការសម្តែង។ ក្រៅពីនេះ ក្រុមការងារបានជួបសម្ភាសអ្នកធ្វើការក្នុងផ្នែកសិប្បកម្ម និងការធ្វើម្ហូប, សិល្បៈសោតទស្សន៍, សិល្បៈសូនរូប, ព្រមទាំងអក្សរសិល្ប៍ និងការបោះពុម្ពផ្សាយ។

ខណៈសិល្បករ និងប្រតិបត្តិករវប្បធម៌វប្បធម៌មួយចំនួនតូច បានចាត់ទុកខ្លួនជាអ្នកប្រកបរបរអាជីវកម្មលក្ខណៈគ្រួសារ, ហើយអ្នកខ្លះទៀតចាត់ទុកខ្លួនជាអ្នកធ្វើការឯករាជ្យ, បុគ្គលស្វ័យនិយោជន៍ និងអ្នកស្ម័គ្រចិត្ត ដែលបានធ្វើការដោយពុំមានកិច្ចព្រមព្រៀង ឬកិច្ចសន្យាជាលាយលក្ខណ៍អក្សរឡើយ។ ភាគច្រើន បុគ្គលស្វ័យនិយោជន៍ នៅខាងផ្នែកសិល្បៈតន្ត្រី និងទស្សនីយភាព ហើយចំណូលប្រចាំឆ្នាំរបស់ពួកគាត់អាស្រ័យតាមរដូវកាល។ ដូច្នេះ កត្តានេះក៏ជាមូលហេតុដែលនាំឱ្យចំណូលរបស់ពួកគាត់ តិចជាងចំណូលរបស់អ្នកធ្វើការផ្នែកសិល្បៈសូនរូប, សិល្បៈសោតទស្សន៍ និងសិល្បៈធ្វើម្ហូប និងសិប្បកម្ម ដោយភាគច្រើនចំណូលរបស់ពួកគាត់ជាមធ្យម លើសពីអត្រាផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗ (GDP per capita) ដែលនេះអាចបង្ហាញថា ពួកគាត់ចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចរបស់ប្រទេស។ ដោយសារការអប់រំ និងចំណូលកម្រិតទាបសិល្បករ និងអ្នកធ្វើការក្នុងផ្នែកតន្ត្រី និងទស្សនីយភាពងាយនឹងមានការធ្លាក់ចុះសេដ្ឋកិច្ច ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីជំងឺរាតត្បាត។ ស្ទើរតែគ្រប់សិល្បករ និងប្រតិបត្តិករវប្បធម៌វប្បធម៌ បានអះអាងថាពួកគាត់មិនបានទទួលជំនួយគាំទ្រណាមួយឡើយ ក្នុងអំឡុងពេលដែលពួកគាត់ទទួលរងផលប៉ះពាល់ពីជំងឺរាតត្បាត។ សិល្បករ និងប្រតិបត្តិករវប្បធម៌ស្ទើរតែទាំងអស់ ពុំមានទំនាក់ទំនងជាមួយសមាគម ឬអង្គការសមាជិកភាពជារដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលណាមួយឡើយ ដោយពួកគាត់មិនបានដឹងថាស្ថាប័នទាំងនោះអាចជួយអ្វីដល់ពួកគាត់ក្នុងគ្រាមានវិបត្តិនេះ។ សិល្បករ និងអ្នកធ្វើការសិល្បៈប្រមាណជា ៤៥ នាក់ បាននិយាយថា ពួកគាត់កំពុងជំពាក់បំណុលសាច់ញាតិស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬធនាគារ។

ទោះបីជាសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ជួបនឹងការលំបាកទាំងអស់នោះក៏ដោយ ពួកគាត់ស្ទើរតែទាំងអស់បាននិយាយថា ពួកគាត់នឹងមិនប្តូរអាជីពឡើយ។ មានភាគតិចនៃពួកគាត់បាននិយាយថានឹងផ្លាស់ប្តូរអាជីពរបស់ខ្លួន ខណៈសិល្បករមួយចំនួនទៀតនៅមិនទាន់ច្បាស់។ ដើម្បីឱ្យអាជីពរបស់ពួកគាត់កាន់តែរីកចម្រើននៅក្នុងយុគសម័យបច្ចេកវិទ្យាឌីជីថលនេះ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ប្រហែលជា ៤៥% ចង់បានរៀនជំនាញខាងផ្នែកបច្ចេកវិទ្យាឌីជីថល។ ការសិក្សាបានអង្កេតឃើញថា សិល្បករ និងប្រតិបត្តិករវប្បធម៌ទាំងអស់សុទ្ធតែមានទូរស័ព្ទដៃវៃឆ្លាត និងសុទ្ធតែអាចភ្ជាប់អ៊ិនធឺណិតបាន។

សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ក្រៅប្រព័ន្ធ ជាពិសេសសិល្បករ និងអ្នកធ្វើការខាងផ្នែកតន្ត្រី និងទស្សនីយភាព មានការប្រឈមមុខនឹងផលលំបាកជាច្រើន ហើយផលលំបាកភាគច្រើនបណ្តាលមកពីកង្វះការទទួលស្គាល់ពីអ្នកពាក់ព័ន្ធនានា ទោះបីជាពួកគាត់បានប្តេជ្ញាចិត្តអភិរក្សប្រពៃណីវប្បធម៌ដ៏មានតម្លៃរបស់កម្ពុជាក៏ដោយ។ ក្រោយមក ពួកគាត់បានបញ្ជាក់ថា ពួកគាត់មិនអាចរស់បានដោយសារចំណូលដែលបានមកពីការសម្តែងនោះទេ ប៉ុន្តែពួកគាត់ចង់អភិរក្សវប្បធម៌។ សិល្បករ និងអ្នកធ្វើការសិល្បៈស្ទើរតែទាំងអស់បាននិយាយថា ពួកគាត់មិនធ្លាប់ទទួលបានអត្ថប្រយោជន៍នៃប្រព័ន្ធគាំពារសង្គមឡើយ ។ តាមរយៈការចូលរួមចំណែកដ៏សំខាន់ក្នុងការជួយអភិរក្សវប្បធម៌កម្ពុជា និងការចូលរួមចំណែកយ៉ាងសកម្មក្នុងវិស័យសេដ្ឋកិច្ច សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ទាំងអស់នេះ គួរតែទទួលបានអត្ថប្រយោជន៍ពីជំនួយគាំទ្ររបស់រដ្ឋាភិបាល។

## អក្សរកាត់

| | |
|---|---|
| CCIs | : ឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ |
| CICADA | : សមាគមដើម្បីការអភិវឌ្ឍ និងការគាំទ្រឧស្សាហកម្មកែច្នៃនៃកម្ពុជា |
| CIs | : ឧស្សាហកម្មវប្បធម៌ |
| GDP | : ផលិតផលក្នុងស្រុកសរុប |
| ID Poor | : កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ |
| ILO | : អង្គការពលកម្មអន្តរជាតិ |
| IFCD | : មូលនិធិអន្តរជាតិដើម្បីភាពផ្សេងៗគ្នានៃវប្បធម៌ |
| LGBT | : សហគមន៍អ្នកស្រលាញ់ភេទដូចគ្នា |
| MoCFA | : ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| NSSF | : បេឡាជាតិសន្តិសុខសង្គម |
| SC | : គណៈកម្មការនាយក |
| UNESCO | : អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ |

## Table of Contents

1

សេចក្តីថ្លែងអំណរគុណ 2

អំពីសមាគមស៊ីកាដា 3

អក្សរកាត់ 5

វិធីសាស្ត្រ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ 12

តើពួកគាត់ជានរណា? 15

ការអប់រំ និងជំនាញវប្បធម៌ 16

សមាជិកភាព និងសម្ព័ន្ធភាព 18

ជីវភាពរស់នៅ 24

ផលប៉ះពាល់នៃជម្ងឺរាតត្បាត 29

ភាពប្រឈម និងសេចក្តីរំពឹងទុក 31

សេចក្តីសន្និដ្ឋាន និងអនុសាសន៍ 34

ឯកសារយោង 37

## ហេតុអ្វីធ្វើការស្រាវជ្រាវ៖ បរិបទ និងសនិទានភាព

នៅកម្ពុជា វិស័យឧស្សាហកម្មវប្បធម៌បានចូលរួមចំណែកយ៉ាងហោចណាស់ក៏ ១.៥៣% នៅក្នុងផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេស។ នៅក្នុងចំនួននេះ មាន ៩១.៤% ជាផលទទួលបានពីសកម្មភាពវប្បធម៌ចម្បងៗ និង ៨.៦% ជាផលទទួលបានពីខ្សែសង្វាក់ផ្គត់ផ្គង់ពាក់ព័ន្ធ ដូចជាឧបករណ៍សម្ភារសម្រាប់សកម្មភាពវប្បធម៌។ ក្នុងឆ្នាំ២០១១ នៅក្នុងចំណោមប្រជាជនដែលមានការងារធ្វើនៅកម្ពុជា ចំនួន ០.៥៤% ជាអ្នកដែលមានការងារនៅតាមគ្រឹះស្ថានវប្បធម៌ (ប្រជាជន ៤១ ៥៤៣ នាក់: ប្រុស ៥៨.៣% និង ស្រី ៤១.៧%)។ ៥៩.៦% មានអាជីពការងារនៅក្នុងវិស័យវប្បធម៌ និង ៤០.៤% មានអាជីពការងារខាងផ្នែកផ្គត់ផ្គង់ឧបករណ៍និងគាំទ្រ[1]។

ការចូលរួមចំណែករបស់វិស័យឧស្សាហកម្មវប្បធម៌នៅក្នុងផលិតផលក្នុងស្រុកសរុប (GDP) ពិតជាសំខាន់ណាស់ ប៉ុន្តែវិស័យនេះត្រូវបានគេចាត់ទុកថាជាសកម្មភាពវប្បធម៌ឯកជន និងក្រៅប្រព័ន្ធទៅវិញ។ ទិន្នផល

[1] កម្ពុជា-សូចនាករសេដ្ឋកិច្ច-ការចូលរួមចំណែកនៅក្នុង GDP របស់សកម្មភាពវប្បធម៌, បានទាញយកនៅថ្ងៃទី ០២ កុម្ភៈ ២០២២ ពី https://en.unesco.org/creativity/sites/creativity/files/cdis/docs/cdis_analytical_brief_cambodia_2.pdf

និងអត្ថប្រយោជន៍ដែលបានមកពីសកម្មភាពវប្បធម៌ក្រៅប្រព័ន្ធ ត្រូវបានគេវាយតម្លៃទាបមិនស្មើនឹងទិន្នផលពិតរបស់វិស័យនេះឡើយ។ សេដ្ឋកិច្ចក្រៅប្រព័ន្ធ និងស្ថាប័នមិនផ្តោតលើទីផ្សារនៃវិស័យឧស្សាហកម្មវប្បធម៌ (CIs) និងសកម្មភាពដែលទាក់ទងនឹងឧស្សាហកម្មវប្បធម៌បែបនេះ មិនទាន់ត្រូវបានគេបូកបញ្ចូលជាផ្លូវការទៅក្នុងផលិតផលក្នុងស្រុកសរុប (GDP) នោះទេ។ ដូចគ្នានឹងសកម្មភាពសេដ្ឋកិច្ចក្រៅផ្លូវការផ្សេងៗទៀតដែរ វិស័យឧស្សាហកម្មវប្បធម៌ក្រៅប្រព័ន្ធ មិនបានទទួលអត្ថប្រយោជន៍អ្វីពីគម្រោងគាំពារសង្គមរបស់រដ្ឋឡើយ (ជាពិសេសអំឡុងវិបត្តិជំងឺរាតត្បាត) និងគោលនយោបាយសារពើពន្ធផ្សេងទៀតសម្រាប់វិស័យឧស្សាហកម្មវប្បធម៌នៅឡើយ។

វិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ (CCIs) គឺជាបេះដូងនៃសេដ្ឋកិច្ចច្នៃប្រតិដ្ឋ ។ ជំងឺកូវីដ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់វិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ ដោយបន្សល់នូវភាពអត់ការងារធ្វើជាច្រើនប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យមានការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គម ដែលជះឥទ្ធិពលអវិជ្ជមានរយៈពេលយូរដល់សិល្បករ និងអ្នកធ្វើការក្នុងផ្នែកឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ទៀតផង។ ទាំងឧស្សាហកម្មទស្សនីយភាពផ្ទាល់ និងអនឡាញ ទទួលរងការប៉ះទង្គិចខ្លាំងជាងគេបំផុត ដោយប៉ះពាល់ដល់ជីវភាពរស់នៅ ការធ្វើដំណើររបស់សិល្បករ ទំនាក់ទំនងទីផ្សារ និងសេរីភាពសិល្បៈ រួមជាមួយផលលំបាកកាន់តែធំជាងនេះទាក់ទងនឹងខ្សែសង្វាក់តម្លៃសម្រាប់អ្នកផ្តល់សេវា និងអ្នកផ្គត់ផ្គង់ (UNESCO, ២០២១)។ ជំងឺរាតត្បាតពិតជាបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វិស័យទេសចរណ៍ដែលសិល្បករ និងអ្នកធ្វើការក្នុងវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ជាប់ពាក់ព័ន្ធខ្លាំងបំផុត។ វិបត្តិនៅក្នុងវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ដែលបណ្តាលមកពីជំងឺរាតត្បាត ធ្វើឱ្យស្ថានភាពនិន្នាការដែលមានស្រាប់ពីមុនកាន់តែមានសភាពធ្ងន់ធ្ងរឡើង។ វាបង្ហាញពីវិសមភាព និងភាពមិនច្បាស់លាស់ដែលមានពីមុននៃវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌នៅស្ទើរគ្រប់ប្រទេសទូទាំងពិភពលោក ជាពិសេសបណ្តាប្រទេសដែលរដ្ឋមិនទាន់មានគម្រោងគាំពារសង្គមសម្រាប់វិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌នេះ។ ការស្តារឡើងវិញនៃសេដ្ឋកិច្ចបន្ទាប់ពីជំងឺរាតត្បាត មានដំណើរយឺត និងទំនងជាងាយរងគ្រោះកាន់តែធ្ងន់ធ្ងរដោយសារការផ្លាស់ប្តូរប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក។ ប្រាកដណាស់ វិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌នៅកម្ពុជា មិនត្រូវបានលើកលែងពីការផ្លាស់ប្តូរដ៏គំហុកនេះឡើយ។

- **វត្ថុបំណង និងវិសាលភាពនៃគម្រោងស្រាវជ្រាវ**

ការស្រាវជ្រាវនេះកំណត់បង្ហាញពីទិដ្ឋភាពនៅក្នុងវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ ដោយផ្តោតទៅលើធនធានមនុស្ស និងធនធានសម្ភារ ស្ថានភាពសេដ្ឋកិច្ចសង្គម ភាពប្រឈម និងសេចក្តីរំពឹងទុករបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌នៅកម្ពុជា។ លទ្ធផលនៃការស្រាវជ្រាវមិនត្រឹមតែអាចផ្តល់ជាព័ត៌មានមូលដ្ឋានអំពីសិល្បករ និងអ្នកធ្វើក្នុងវិស័យវប្បធម៌ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចផ្តល់អនុសាសន៍ជាគោលនយោបាយសម្រាប់អ្នកពាក់ព័ន្ធខាងរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ដែលសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ក្រៅប្រព័ន្ធកំពុងជួបប្រទះថែមទៀតផង។

ការស្រាវជ្រាវនេះផ្តោតលើស្វ័យនិយោជន៍ក្រៅប្រព័ន្ធ និងប្រាក់ឈ្នួលសម្រាប់ការងារក្រៅប្រព័ន្ធ ដែលបានកំណត់ដូចតទៅ៖ អ្នកទាំងឡាយណាដែលបានធ្វើការរហូតមកដល់ពេលនេះ និងធ្លាប់បានធ្វើការនៅក្នុងវិស័យឧស្សាហកម្មវប្បធម៌ ជាអ្នកធ្វើការឯករាជ្យ អ្នកធ្វើការចុះកិច្ចសន្យារយៈពេលខ្លី បុគ្គលស្វ័យនិយោជន៍ សហគ្រិន អ្នកស្ម័គ្រចិត្តដោយគ្មានប្រាក់កម្រៃជាក់លាក់ និងអ្នកទាំងឡាយណាដែលពុំបានចុះបញ្ជីជាផ្លូវការជាមួយនឹងស្ថាប័នរដ្ឋាភិបាល (សូមមើលនិយមន័យនៅផ្នែកខាងក្រោម)។ សិល្បករ និងអ្នកធ្វើការសិល្បៈទាំងនេះ គឺជាអ្នកដែលស្វែងរកការងារទៅតាមរដូវកាល និងម្តងម្កាល។ គម្រោងស្រាវជ្រាវនេះមិនសិក្សាអំពីអ្នកទាំងឡាយណាដែលមានការងារ

ជាប់លាប់រយៈពេលយូរ ហើយមានស្ថេរភាពប្រាក់ចំណូល និងទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមដូចជា ផ្នែកសុខភាព និងសុខុមាលភាពឡើយ។

ការស្ទង់មតិតាមអនឡាញ និងដោយផ្ទាល់បានធ្វើឡើងពីខែមិថុនា ដល់តុលា ឆ្នាំ២០២២ ហើយការសម្អាត និងការវិភាគទិន្នន័យធ្វើឡើងពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០២២។ សិក្ខាសាលាផ្ទៀងផ្ទាត់ ដើម្បីបង្ហាញពីលទ្ធផលបឋមនៃការស្ទង់មតិ និងការវិភាគនេះបានធ្វើឡើងនៅក្នុងខែកុម្ភៈ ឆ្នាំ២០២៣ នៅខេត្តបាត់ដំបង និងសៀមរាប។ ប្រាក់ចំណូលដែលបានលើកមកបង្ហាញនៅក្នុងរបាយការណ៍នេះ គឺជាប្រាក់ចំណូលដែលសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌រកបានត្រឹមខែតុលា ឬវិច្ឆិកា ក្នុងឆ្នាំ២០២២។

- **តើឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ជាអ្វី?**

វាជារឿងសំខាន់ក្នុងការកំណត់និយមន័យនៃពាក្យឧស្សាហកម្ម និងពាក្យដែលទាក់ទងនឹងវិស័យនេះ ដើម្បីយល់អំពីឧស្សាហកម្មវប្បធម៌ក្រៅប្រព័ន្ធ។ វប្បធម៌ ត្រូវបានគេស្គាល់ថាជា "ទម្រង់លក្ខណៈដែលទាក់ទងនឹងអារម្មណ៍ បញ្ញា សម្ភារ និងស្មារតីណាមួយក្នុងសង្គម ឬក៏ជាក្រុមសង្គមដែលរួមបញ្ចូលទាំងសិល្បៈ និងអក្សរសិល្ប៍ ទាំងរបៀបនៃការរស់នៅ ពោលគឺរបៀបនៃការរស់នៅរួមគ្នា ប្រព័ន្ធគុណតម្លៃ ប្រពៃណី និងជំនឿ" (UNESCO, ២០០១)។ ឧស្សាហកម្មវប្បធម៌ អាចត្រូវបានគេយល់ថាជា៖

វិស័យនៃសកម្មភាពដែលមានរៀបចំ ហើយវត្ថុបំណងចម្បងនៃសកម្មភាពទាំងនោះ គឺជាការផលិត ឬការផលិតបន្ត, ការផ្សព្វផ្សាយ, ការចែកចាយ ឬការជួយជួញដូរទំនិញ, សេវាកម្ម និងសកម្មភាពនានាដែលកើតចេញពីប្រភពវប្បធម៌ សិល្បៈ ឬមតិក។ ឧទាហរណ៍ សិប្បកម្ម ភាពយន្ត សិល្បៈទស្សនីយភាព និងការរចនា[១]។

ឧស្សាហកម្មវប្បធម៌ តែងតែជាប់ទាក់ទងនឹងពាក្យមួយទៀតគឺ ឧស្សាហកម្មច្នៃប្រតិដ្ឋ ដែលត្រូវគេយល់ថាជា ឧស្សាហកម្មទាំងឡាយណាដែលមានដើមកំណើតនៅក្នុងការច្នៃប្រតិដ្ឋ ជំនាញ និងទេពកោសល្យរបស់បុគ្គល ដែលអាចទទួលបានការងារ និងអាចបង្កើតទ្រព្យ តាមរយៈការបង្កើត និងការទទួលផលពីកម្មសិទ្ធិបញ្ញា"[១]។ ឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ តែងតែត្រូវបានដាក់ចូលទៅក្នុងអេកូឡូស៊ីនៃសេដ្ឋកិច្ចច្នៃប្រតិដ្ឋ។ នេះរួមមាន៖ សិល្បៈ វប្បធម៌ អាជីវកម្ម និងបច្ចេកវិទ្យា។ ស្ថិតចំណុចស្នូលនៃសេដ្ឋកិច្ចច្នៃប្រតិដ្ឋ ឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ គឺជាទម្រង់នៃការធ្វើអាជីវកម្ម ដែលសំដៅលើផលិតកម្ម, ទំនិញ និងសេវាកម្ម ដែលអាចជួញដូរបាន។ ឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ មានទិដ្ឋភាពវប្បធម៌ចំនួន២ គឺឧស្សាហកម្មវប្បធម៌ផ្សេងៗ និងសិល្បៈច្នៃប្រតិដ្ឋ (សូមមើល រូប ១)។



ប្រភព៖  UNESCO and The World Bank, 2021.

ខណៈដែលឧស្សាហកម្មវប្បធម៌ចម្បងផ្សេងទៀតរួមមាន ភាពយន្ត, សារមន្ទីរ, វិចិត្រសាល, បណ្ណាល័យ និងសិល្បៈថតរូប, សិល្បៈច្នៃប្រតិដ្ឋរួមមានអក្សរសិល្ប៍, តន្ត្រី, សិល្បៈទស្សនីយភាព និងសិល្បៈសូនរូប។ ការច្នៃប្រតិដ្ឋនៅក្នុងសិល្បៈ គឺជាលំដាប់លំដោយនៃគំនិត និងសកម្មភាព ដែលនាំឆ្ពោះទៅដល់ស្នាដៃដើម និងសមរម្យមួយ (Lubart, 2001)។ ដូច្នេះហើយ សិល្បៈច្នៃប្រតិដ្ឋបង្កើតភាពដើម និងភាពច្នៃប្រតិដ្ឋនៅគ្រប់ទិដ្ឋភាពសិល្បៈ។ ការច្នៃប្រតិដ្ឋ និងការផលិតជាភាពដើម និងភាពច្នៃប្រតិដ្ឋ មានទំនាក់ទំនងជាមួយនឹងអ្វីមួយដែលហៅថា “សិល្បៈសហសម័យ”។ នៅក្នុងការសិក្សាអំពីសិល្បៈច្នៃប្រតិដ្ឋ និងវប្បធម៌ សិល្បៈសហសម័យត្រូវបានគេប្រើយ៉ាងទូលំទូលាយ “សំដៅលើសិល្បៈពេលបច្ចុប្បន្ន និងអតីតកាលថ្មីៗនៃអ្នកច្នៃប្រតិដ្ឋថ្មី ឬនៃគំនិតពិសោធសាកល្បង”[១]។ សិល្បៈសហសម័យគឺជា “សិល្បៈនៃថ្ងៃនេះ”។ ដូច្នេះហើយ វាគឺជាវិស័យអន្តរវិធាន ដែលបង្កើតបានជាផ្នែកមួយនៃឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌។

- ## ប្រភេទផ្សេងៗនៃឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌

ការសិក្សានេះទទួលស្គាល់ភាពជាន់គ្នារវាងឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌។ មានជំនាញនិងប្រភេទជាច្រើន ត្រូវបានធ្វើ កំណត់ថ្នាក់ជាទម្រង់ឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ ដូចនៅក្នុងតារាង ១។ អង្គការយូណេស្កូ និងធនាគារពិភពលោក (២០២១) បានកំណត់ទម្រង់ចម្បងចំនួន ៧ និងទម្រង់តូចៗជាច្រើន សម្រាប់ឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌។

**ប្រភេទឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌**

**សិល្បៈទស្សនីយភាព**
- ល្ខោន
- តន្ត្រី
- របាំ
- មហោស្រព
- បុណ្យ និងពិព័រណ៍

**មតិកវប្បធម៌អរូបី**
- មហោស្រព
- កិច្ចពិធី និងការអនុវត្តសង្គម
- ប្រពៃណីផ្ទាល់មាត់
- ចំណេះជំនាញ និងសិប្បកម្មប្រពៃណី
- តម្បាញ

**អក្សរសិល្ប៍ និងសារព័ត៌មាន**
- សៀវភៅ
- កាសែត
- ទស្សនាវដ្ដី
- បណ្ណាល័យ
- ពិព័រណ៍សៀវភៅ

**សារព័ត៌មានសកម្ម និងសោតទស្សន៍**
- ភាពយន្ត
- ទូរទស្សន៍ និងវិទ្យុ
- ការផ្សាយ
- ទូរការផ្សាយតាមអ៊ីនធឺណេត
- វីដេអូហ្គេម

**ការរចនា និងសេវាកម្មច្នៃប្រតិដ្ឋ**
- ស្ថាបត្យកម្ម
- រចនាម៉ូដ
- រចនាក្រាហ្វិក
- រចនាផ្ទៃក្នុង
- ការផ្សព្វផ្សាយ

**សកម្មភាពទេសចរណ៍ និងមតិក**
- កន្លែងប្រវត្តិសាស្ត្រ
- កន្លែងបុរាណវិទ្យា មតិកធម្មជាតិ និងទេសភាពវប្បធម៌
- សារមន្ទីរ សកម្មភាពទេសចរណ៍
- សកម្មភាពទេសចរណ៍

| សិល្បៈសូនរូប | | |
|---|---|---|
| • វិចិត្រសិល្បៈ | • សិល្បៈចតរូប | • សិប្បកម្ម |

*តារាង ១ : ទម្រង់តូចៗនៃឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌*

ប្រភព៖ បានសម្រួលពីអង្គការយូណេស្កូ និងធនាគារពិភពលោក, ២០២១

យោងតាមបរិបទឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌របស់ប្រទេសកម្ពុជា ការសិក្សានេះសម្រេចយក និងកែសម្រួលទិន្នន័យរបស់អង្គការយូណេស្កូ និងធនាគារពិភពលោក (២០២១) និងបានកំណត់ ឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ដូចខាងក្រោម។ ការសិក្សាបានប្រើប្រាស់ទម្រង់ទាំងនេះ ដើម្បីកំណត់សិល្បករ និងអ្នកធ្វើការក្នុងវិស័យឧស្សាហកម្មវប្បធម៌ក្រៅប្រព័ន្ធ ដោយយោងទៅតាមការងារ និងជំនាញរបស់ពួកគាត់។

- សិល្បៈទស្សនីយភាព ៖ ល្ខោន, របាំ, សៀក
- តន្ត្រី ៖ ចម្រៀងប្រពៃណី, ចម្រៀងសម័យ
- សិល្បៈសូនរូប ៖ គំនូរ, ការបង្ហាញស្នាដៃបែបដំឡើង, សិល្បៈចតរូប, ចម្លាក់, សិប្បកម្ម
- សោតទស្សន៍ ៖ ភាពយន្ត, ភាពយន្តឯកសារ, សិល្បៈវីដេអូ, គំនូរជីវចល
- អក្សរសិល្ប៍ និងសារព័ត៌មាន/ការបោះពុម្ពផ្សាយ៖ សៀវភៅ, ទស្សនាវដ្តី, កំណាព្យ, អត្ថបទកុន, បណ្ណាល័យ
- សិប្បកម្ម និងសិល្បៈធ្វើម្ហូប៖ ឈើ, ដែក, ថ្ម, ចុងភៅ, អលង្ការ, តម្បាញ, កុលាលភាជន៍, ស្បែក, សិល្បៈធ្វើម្ហូប
- មតិកវប្បធម៌ ៖ មតិកធម្មជាតិ និងវប្បធម៌, ទីបុរាណវិទ្យា, សារមន្ទីរ, បណ្ណសារដ្ឋាន

## • តើអ្វីជាឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ក្រៅប្រព័ន្ធ?

មិនមានការកំណត់និយមន័យ ឬទស្សនៈដ៏រឹងមាំមួយអំពីឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ក្រៅប្រព័ន្ធនៅឡើយទេ។ ពាក្យថា «ក្រៅប្រព័ន្ធ» គឺជាការកំណត់ហៅដោយស្ថាប័នរដ្ឋផ្នែកសិល្បៈ ដើម្បីចែកឱ្យដាច់ពីគ្នារវាងឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ។ «ក្រៅប្រព័ន្ធ» គឺជាផ្នែកមួយនៃអាជីវកម្ម និងសេដ្ឋកិច្ចនៃឧស្សាហកម្មណាមួយ ។ នៅក្នុងបរិបទសេដ្ឋកិច្ចវិញ សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាសេដ្ឋកិច្ចស្រមោល ដែលមិនបានចុះបញ្ជីជាផ្លូវការ ដូច្នេះហើយ វាក៏មិនត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ស្ថិតិជាផ្លូវការនៃសកម្មភាពសេដ្ឋកិច្ចឡើយ (Skovronska, 2021)។ ការផលិតទំនិញ និងសេវាកម្មតម្រូវតាមទីផ្សារ ទោះស្របច្បាប់ ឬមិនស្របច្បាប់ក៏ដោយ ក៏មិនត្រូវបានរាប់បញ្ចូលនៅក្នុងការប៉ាន់ប្រមាណជាផ្លូវការអំពីផលិតផលក្នុងស្រុកសរុប (GDP) ដែរ (Smith, 1985)។ «ក្រៅប្រព័ន្ធ» គឺជាភាពស្របច្បាប់នៃសកម្មភាពដែលចូលរួមចំណែកនៅក្នុងសេដ្ឋកិច្ច។

យោងតាមគំនិតស្តីពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ក្រៅប្រព័ន្ធ អាចត្រូវបានគេយល់ថាជាការដោះដូរនៃទំនិញ និងសេវាកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ក្នុងវិស័យឧស្សាហកម្ម ដែលមិនបានចុះបញ្ជីជាផ្លូវការដោយស្ថាប័នរដ្ឋ (Skovronska, 2021)។ វាមិនទាន់ត្រូវបានគេទទួលស្គាល់ថាជាការចូលរួមចំណែកនៅក្នុងសេដ្ឋកិច្ចផ្លូវការរបស់ជាតិនៅឡើយ។ អ្នកធ្វើការក្នុងវិស័យឧស្សាហកម្មវប្បធម៌ក្រៅប្រព័ន្ធកអាចចាត់ចូលក្នុងប្រភេទការងារក្រៅប្រព័ន្ធដែរ។ បើតាមការកំណត់នៅក្នុងផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធរបស់អង្គការពលកម្មអន្តរជាតិ (ILO)

ការងារដែលចាត់ទុកថាក្រៅប្រព័ន្ធមាន ស្វ័យនិយោជន៍ និង ការងារទទួលប្រាក់តាមម៉ោង។ ប្រភេទនីមួយៗនេះត្រូវបានកំណត់ដូចតទៅ៖

*ស្វ័យនិយោជន៍ក្រៅប្រព័ន្ធ ៖*

- និយោជកក្នុងសមាគម/សហគ្រាសវប្បធម៌ក្រៅប្រព័ន្ធ
- សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ដោយខ្លួនឯងផ្ទាល់នៅក្នុងអង្គភាព/សហគ្រាសវប្បធម៌ក្រៅប្រព័ន្ធ
- សិល្បករ/អ្នកធ្វើការក្នុងវិស័យវប្បធម៌ដែលជួយសមាជិកគ្រួសារឱ្យធ្វើអាជីវកម្មក្នុងអង្គភាព/សហគ្រាសវប្បធម៌ក្នុង និងក្រៅប្រព័ន្ធ
- សមាជិករបស់ផលិតករវប្បធម៌ក្រៅប្រព័ន្ធ

*ការងារធ្វើតាមម៉ោងក្រៅប្រព័ន្ធ ៖*

នេះរួមមាននិយោជិតដែលត្រូវបានជួល (ដោយពុំទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គម) ដោយសហគ្រាសវប្បធម៌ក្នុង ឬក្រៅប្រព័ន្ធ ឬ សិល្បករ/អ្នកធ្វើការសិល្បៈដែលត្រូវបានបង់ប្រាក់ឈ្នួលដោយសហគ្រាសវប្បធម៌ទាំងក្នុង និងក្រៅប្រព័ន្ធ។ ប្រភេទផ្សេងៗខាងក្រោម ត្រូវបានចាត់ទុកថាជាភាពមានការងារធ្វើតាមម៉ោងក្រៅប្រព័ន្ធ៖

- និយោជិតនៃសហគ្រាសវប្បធម៌ក្រៅប្រព័ន្ធ
- សិល្បករ/អ្នកធ្វើការក្នុងវិស័យវប្បធម៌/និងអ្នកសម្តែងដែលទទួលបានប្រាក់កម្រៃមិនទៀងទាត់
- អ្នកធ្វើការក្នុងវិស័យវប្បធម៌/សិល្បករ ធ្វើការពាក់កណ្តាលពេល, បណ្តោះអាសន្ន ឬស្ម័គ្រចិត្ត
- សិល្បករ/អ្នកធ្វើការក្នុងវិស័យវប្បធម៌ក្នុងស្រុកដែលទទួលបានប្រាក់កម្រៃ
- សិល្បករ/អ្នកធ្វើការក្នុងវិស័យវប្បធម៌មានកិច្ចសន្យា ដែល ប្រាក់ខែ ឬប្រាក់កម្រៃ មិនបានចុះបញ្ជីក្នុងប្រព័ន្ធគាំពារសង្គម និងប្រាក់ខែរដ្ឋ។
- សិល្បករ/អ្នកធ្វើការក្នុងវិស័យវប្បធម៌ដែលមិនបានចុះបញ្ជី ឬប្រកាសបញ្ជី

ផ្អែកលើគោលគំនិតនៃឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ និងការនៅក្រៅប្រព័ន្ធ ការសិក្សានេះផ្តោតលើទិដ្ឋភាពចំនួនពីរនៃការងារ និងឱកាសក្នុងឧស្សាហកម្មវប្បធម៌ក្រៅប្រព័ន្ធ ដែលក្នុងនោះមានស្វ័យនិយោជន៍ក្រៅប្រព័ន្ធ និងការងារតាមម៉ោងក្រៅប្រព័ន្ធ។ សិល្បករ/អ្នកធ្វើការក្នុងវិស័យវប្បធម៌នៃប្រភេទទាំងពីរនេះ ក៏រួមបញ្ចូល "អ្នកធ្វើការឯករាជ្យឯកត្តបុគ្គល" ដែលមិនធ្វើការផ្អែកលើពេលវេលា ឬកិច្ចសន្យារយៈពេលយូរ ឬអចិន្ត្រៃយ៍ឱ្យអង្គការ, ក្រុមហ៊ុន ឬសហគ្រាសណាមួយ ទោះបានចុះបញ្ជីជាលក្ខណៈផ្លូវការ ឬក្រៅផ្លូវការជាមួយស្ថាប័នរដ្ឋក៏ដោយ។ អ្នកធ្វើការឯករាជ្យឯកត្តបុគ្គលទាំងនេះ ត្រូវបានគេទទួលស្គាល់ជាផ្លូវការ និងមិនផ្លូវការ (បានចុះឈ្មោះជាសមាជិកភាព) ដោយស្ថាប័នរដ្ឋ ឬអង្គភាពឯកជននៅក្នុងឧស្សាហកម្មវប្បធម៌ ប៉ុន្តែពួកគេមិនបានចុះបញ្ជីតាមផ្លូវច្បាប់នៅក្នុងប្រព័ន្ធគាំពារសង្គមទេ។ នេះមិនមែនដោយសារតែពួកគេមិនមានបញ្ជីលេខបង់ពន្ធផ្ទាល់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏ដោយសារមិនធ្លាប់មានយន្តការ ឬទម្រង់ណាមួយ សម្រាប់ឱ្យអ្នកធ្វើការក្នុងវិស័យវប្បធម៌ទាំងនេះអាចមានលទ្ធភាពប្រកាសពន្ធលើប្រាក់ចំណូលរបស់ពួកគេនៅឡើយ។

## វិធីសាស្ត្រ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

- ### អ្នកឆ្លើយតបសម្ភាសន៍

ការសិក្សានេះផ្អែកលើចម្លើយដែលទទួលបានពីអ្នកឆ្លើយតបចំនួន ៤១៤ នាក់។ អ្នកឆ្លើយទាំងនេះ ត្រូវបានអញ្ជើញដោយមិនបានកំណត់ទុកជាមុន ដើម្បីចូលរួមនៅក្នុងការស្ទង់មតិដោយប្រើវិធីសាស្ត្រខាងក្រោម៖

- វិធីបោះបាល់បន្ត : ការសុំឱ្យអ្នកឆ្លើយតបសម្ភាសន៍ជ្រើសរើសអ្នកឆ្លើយម្នាក់ទៀត ដើម្បីឆ្លើយនឹងកម្រងសំណួរតាមអនឡាញ និងកិច្ចសម្ភាសន៍ដោយផ្ទាល់;
- វិធីជ្រើសរើសដោយព្រាវៈ ក្រុមស្រាវជ្រាវចែកចាយតំណភ្ជាប់នៃកម្រងសំណួរអនឡាញ និងប្រកាសជាសាធារណៈ ដើម្បីឱ្យអ្នកធ្វើការដែលមានសក្តានុពលក្នុងវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ចូលរួមផ្តល់ចម្លើយនិង
- ប្រសិនបើអ្នកធ្វើការ និងសិល្បករក្នុងវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋនិងវប្បធម៌ មិនអាចទទួលបានកម្រងសំណួរតាមអនឡាញទេ ប៉ុន្តែបង្ហាញពីចំណាប់អារម្មណ៍ចូលរួមនៅក្នុងការស្ទង់មតិនេះ ក្រុមស្រាវជ្រាវបានទាក់ទងគាត់ដើម្បីសម្ភាសតាមទូរស័ព្ទ។

នៅពេលអនុវត្តការស្ទង់មតិនេះ ក្រុមស្រាវជ្រាវមិនបានដឹង និងគ្មានព័ត៌មានប្រជាសាស្ត្រ (ទាំងអាសយដ្ឋានទំនាក់ទំនង និងកន្លែងដែលពួកគាត់រស់នៅ) ស្តីពីសិល្បករ និងអ្នកធ្វើការខាងឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ស្រាប់នោះទេ។ ដូចនេះ ការអញ្ជើញឱ្យចូលរួមក្នុងការស្ទង់មតិធ្វើឡើងដោយព្រាវសុទ្ធសាធ។ នេះអាចនៅមានសិល្បករ និងអ្នកធ្វើការ ដែលមានសក្តានុពលក្នុងវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ដែលក្រុមការងារមិនបានទាក់ទង ប៉ុន្តែធនធាន និងពេលវេលាក៏ជាមូលហេតុដែលបានធ្វើឱ្យពួកយើងមិនអាចស្វែងរក និងអញ្ជើញពួកគាត់ទាំងអស់ដើម្បីចូលរួមនៅក្នុងការសិក្សានេះបានដែរ ជាពិសេសចំពោះអ្នកនៅតំបន់ដាច់ស្រយាល។

- ### តំបន់គោលដៅ

ការសិក្សាមានបំណងយកអ្នកតំណាងមកពីគ្រប់ខេត្តនៅក្នុងប្រទេស។ ទោះជាយ៉ាងណាក៏ដោយ ដោយសារពេលវេលា និងធនធានមានកម្រិត ការស្រាវជ្រាវនេះបានដៅយកតែតំបន់ណាដែលមានសិល្បករ និងអ្នកធ្វើការវប្បធម៌ចំនួនច្រើនបំផុត។ បន្ថែមពីនេះ ក្រុមស្រាវជ្រាវបានលើកទឹកចិត្តដល់សិល្បករទាំងអស់នៅតាមបណ្តាខេត្តផ្សេងៗទៀត ដែលមានចំនួនសិល្បករតិចជាង ដូចជាខេត្តមណ្ឌលគិរី រតនគិរី ស្ទឹងត្រែង និងព្រះវិហារ ឱ្យចូលរួមក្នុងការស្ទង់មតិតាមរយៈកម្រងសំណួរអនឡាញ កិច្ចសម្ភាសន៍តាមទូរស័ព្ទ និងកិច្ចសម្ភាសន៍ផ្ទាល់។ សិល្បករដែលបានចូលរួមនៅក្នុងការស្ទង់មតិភាគច្រើនមកពីខេត្តបាត់ដំបង សៀមរាប កំពត ភ្នំពេញ កំពង់ធំ និងកណ្តាល ដែលជាកន្លែងមនុស្សជាច្រើនជឿជាក់ថាជាតំបន់របស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌។ ដើម្បីកាត់បន្ថយភាពលម្អៀងឱ្យកាន់តែតិច ក្រុមស្រាវជ្រាវក៏បានទាក់ទងទៅសិល្បករតាមខេត្តដាច់ស្រយាលផងដែរ ដូចជាខេត្តឧត្តរមានជ័យ និងកោះកុង ដើម្បីចូលរួមនៅក្នុងការស្រាវជ្រាវនេះ។ ដើម្បីគ្របដណ្តប់ឱ្យបានល្អ ការស្រាវជ្រាវនេះបង្ហាញពីទស្សនៈ និងយោបល់យ៉ាងច្រើនដែលតំណាងឱ្យសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ក្រៅប្រព័ន្ធរបស់ប្រទេសដូចដែលបានកំណត់រួចមក។

- ## កម្រងសំនួរ និងការសម្ភាសន៍

ដោយមានការប្រឹក្សាជាប្រចាំជាមួយគណៈកម្មការនាយករបស់សមាគមស៊ីកាដា ក្រុមស្រាវជ្រាវបានបង្កើតកម្រងសំណួរជាគោលមួយ ដោយផ្អែកលើក្របខណ្ឌ និងទស្សនៈនៃវិស័យឧស្សាហកម្មវប្បធម៌ក្រៅប្រព័ន្ធ និងវត្ថុបំណងនៃការសិក្សា។ កម្រងសំណួរសួរពីព័ត៌មានទាក់ទងនឹងប្រជាសាស្ត្រ ជីវភាពរស់នៅ ភាពប្រឈម និងបញ្ហានានា និងសេចក្តីពឹងលើអាជីពរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌។ កម្រងសំណួរនេះ បានយកទៅប្រើប្រាស់ដើម្បីសម្ភាសផ្ទាល់ជាមួយសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ និងបានយកទៅចែកចាយនៅលើបណ្តាញសារព័ត៌មានសង្គម និងគេហទំព័រ ដើម្បីឱ្យពួកគាត់អាចចូលរួមផ្តល់ចម្លើយតាមអនឡាញ។

អំឡុងពេលសម្ភាសន៍ផ្ទាល់ដែលបានធ្វើនៅភ្នំពេញ កំពត កំពង់ធំ បាត់ដំបង និងសៀមរាប ក្រុមស្រាវជ្រាវបានយកឱកាសដើម្បីសួរប្រធានក្រុមចំនួនប្រាំពីរនាក់ រួមទាំងសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌អំពីក្តីបារម្ភ និងភាពប្រឈមនៅក្នុងដំណើរអាជីពរបស់ពួកគាត់ និងបរិបទវិស័យឧស្សាហកម្មវប្បធម៌ក្នុងប្រទេស។ ចម្លើយដែលបានទទួល ការវិភាគអំពីក្តីបារម្ភ កត្តាប្រឈម និងអនុសាសន៍ដែលបានមកពីការសិក្សានេះ បានចេញជាលទ្ធផលសម្រាប់អ្នកពាក់ព័ន្ធទាំងឡាយ។

- ## សិក្ខាសាលាផ្ទៀងផ្ទាត់

ដើម្បីធានាឱ្យមានស្ថេរភាពនៅក្នុងការស្ទង់មតិ និងការវិភាគក្នុងវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ ក្រុមស្រាវជ្រាវបានរៀបចំសិក្ខាសាលាផ្ទៀងផ្ទាត់ចំនួនពីរនៅក្នុងខេត្តបាត់ដំបង និងសៀមរាប។ នៅទីនោះ មានសិល្បករចំនួន ១៩ នាក់ ដែលបានចូលរួមក្នុងការស្ទង់មតិកាលពីលើកមុន បានមកជួបជាមួយក្រុមស្រាវជ្រាវ។ ក្រុមស្រាវជ្រាវបានធ្វើបទបង្ហាញអំពីលទ្ធផលចម្បងៗទៅដល់អ្នកចូលរួម និងបានសុំមតិកែលម្អ និងយោបល់ ដើម្បីធ្វើឱ្យលទ្ធផលដែលទទួលបានពីការស្ទង់មតិមានសុពលភាព។ ក្រុមស្រាវជ្រាវ ក៏បានសួរសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌អំពីក្តីបារម្ភ និងភាពប្រឈមនៅក្នុងអាជីពការងាររបស់ពួកគេបន្ថែមផងដែរ។

- ## ក្រមសីលធម៌ និងការការពារទិន្នន័យ

ការស្រាវជ្រាវនេះ ប្រកាន់ខ្ជាប់ទៅនឹងការអនុវត្តតាមបទដ្ឋានក្រមសីលធម៌វិជ្ជាជីវៈស្រាវជ្រាវសង្គម។ អ្នកឆ្លើយទាំងអស់ បានយល់ព្រមចូលរួមដោយស្ម័គ្រចិត្តនៅក្នុងការស្ទង់មតិតាមអនឡាញ និងការសម្ភាសតាមទូរស័ព្ទ និងដោយផ្ទាល់។ ដើម្បីអនុវត្តតាមបទដ្ឋានក្រមសីលធម៌វិជ្ជាជីវៈ អត្តសញ្ញាណផ្ទាល់ខ្លួនរបស់អ្នកឆ្លើយដូចជា ឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងរូបថត មិនត្រូវបានប្រមូលយកនោះទេ។ ទិន្នន័យដែលផ្តល់ជូននៅក្នុងរបាយការណ៍នេះជាទិន្នន័យអនាមិក។ កន្លែងដែលមានទិន្នន័យផ្ទាល់ខ្លួន ដូចជាព័ត៌មានទំនាក់ទំនង ត្រូវបានផ្តល់ឱ្យដោយស្ម័គ្រចិត្តពីអ្នកឆ្លើយ សមាគមស៊ីកាដា នឹងទទួលទុកព័ត៌មាននេះដោយដាក់ជាលេខសម្ងាត់ការពាររយៈពេលមួយឆ្នាំបន្ទាប់ពីលទ្ធផលស្ទង់មតិនេះត្រូវបានបោះពុម្ពផ្សាយជាសាធារណៈ។ បន្ទាប់ពីមួយឆ្នាំហើយ សមាគមស៊ីកាដានឹងបំផ្លាញចោលទិន្នន័យផ្ទាល់ខ្លួនទាំងអស់នោះ។ របាយការណ៍នឹងមានសម្រាប់អាននៅលើគេហទំព័ររបស់សមាគមស៊ីកាដា។

- **ការត្រួតពិនិត្យលើកិច្ចការស្រាវជ្រាវ**

ការស្រាវជ្រាវនេះ ធ្វើឡើងដោយក្រុមប្រតិបត្តិការងារស្រាវជ្រាវរបស់សមាគមស៊ីកាដា ក្នុងនោះមានអ្នកដឹកនាំការស្រាវជ្រាវ អ្នកសម្របសម្រួល និងជំនួយការ។ រាល់សកម្មភាពស្រាវជ្រាវទាំងអស់ ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់គណៈកម្មការនាយកនៃសមាគមស៊ីកាដា សម្របសម្រួលដោយនាយិកាសមាគមស៊ីកាដា ដែលសុទ្ធសឹងតែជាអ្នកដែលមានបទពិសោធន៍ការងារជាច្រើនឆ្នាំ ក្នុងវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌នៅកម្ពុជា និងថ្នាក់តំបន់។ ក្រុមប្រតិបត្តិការងារស្រាវជ្រាវ បានរាយការណ៍ និងប្រឹក្សាជាមួយគណៈកម្មការនាយករាល់ដំណើរការនៃការស្រាវជ្រាវទាំងអស់ ដើម្បីធានាឱ្យមានភាពហ្មត់ចត់នៅក្នុងការវិភាគលទ្ធផលស្រាវជ្រាវ និងការអនុវត្តក្រមសីលធម៌ប្រកបដោយវិជ្ជាជីវៈ។

# តើពួកគាត់ជានរណា?

**ពីរភាគបីនៃចំនួនសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ក្រៅប្រព័ន្ធដែលចូលរួមក្នុងគម្រោងស្រាវជ្រាវនេះ គឺជាបុរស បើទោះបីជា ស្ត្រីជាតួអង្គដ៏សំខាន់ក្នុងការថែរក្សាប្រពៃណី និងវប្បធម៌ក៏ដោយ។**

ពីរភាគបីនៃចំនួនសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ជាមនុស្សប្រុស ខណៈចំនួនភាគតិច គឺជាមនុស្សដែលមានភេទផ្សេងៗ ដូចជាមនុស្សស្ថិតនៅក្នុងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (រូប ១)។ ភេទប្រុសនៅតែជាភេទដែលមានចំនួនច្រើនជាងគេ ទោះបីជាប្រជាជនកម្ពុជាយល់ឃើញថា ស្ត្រីជាតួអង្គដ៏សំខាន់ក្នុងការថែរក្សាប្រពៃណី និងវប្បធម៌ក៏ដោយ។ បើតាមទំនាក់ទំនងរបស់ពួកយើងជាមួយសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌បានបង្ហាញថា សិល្បករនិងអ្នកធ្វើការក្នុងវិស័យវប្បធម៌ជាស្ត្រី បានចាកចេញពីអាជីពរបស់ពួកគេឆាប់ជាងបុរស ជាពិសេសនៅពេលពួកគាត់បានរៀបការ និងទទួលភារកិច្ចមើលថែកូន។ ៧១.៧% នៃចំនួនសិល្បករបានរៀបការរួចហើយ ២២.៧% នៅលីវ (រូប ៣)។ សិល្បករមួយភាគតូច គឺជាអ្នកលែងលះគ្រួសារ ឬជាអ្នកមានដៃគូ។ ខណៈដែលការងារសិល្បៈវប្បធម៌ ត្រូវបានគេជឿថា ជាការងារសម្រាប់មនុស្សមិនមានពិការភាព ប៉ុន្តែ៧.២% នៃចំនួនសិល្បករដែលបានចូលរួមក្នុងការស្ទង់មតិនេះ អះអាងថា ពួកគាត់គឺជាសិល្បករដែលមានពិការភាព ហើយភាគច្រើនគឺពិការភាពផ្នែករាងកាយ។

មានសិល្បករ និងអ្នកធ្វើការមកពីបណ្ដាខេត្តជាច្រើនជុំវិញប្រទេសកម្ពុជា ប៉ុន្តែភាគច្រើនរស់នៅ និងធ្វើការនៅក្នុងខេត្តបាត់ដំបង សៀមរាប កំពង់ធំ និងភ្នំពេញ (រូប ៤)។ សិល្បករដទៃទៀត រស់នៅកន្លែងផ្សេងៗទៀត ប៉ុន្តែមានការងារធ្វើនៅភ្នំពេញនិងបាត់ដំបង។ មានសិល្បករចំនួន ៥៩ នាក់ បានប្រាប់ពួកយើងថា ពួកគាត់រស់នៅទីក្រុងភ្នំពេញ ប៉ុន្តែសិល្បករប្រមាណ ៧៩ នាក់ឯណោះបានឆ្លើយថាពួកគេកំពុងធ្វើការនៅភ្នំពេញ។ មានសិល្បករ ៩២ នាក់ ដែលកំពុងរស់នៅខេត្តបាត់ដំបង ប៉ុន្តែមានតែសិល្បករ ៨១ នាក់ប៉ុណ្ណោះក្នុងចំណោមពួកគាត់បាននិយាយថា ពួកគាត់ធ្វើការក្នុងខេត្តនេះ។ ភ្នំពេញនិងសៀមរាប គឺជាកន្លែងធ្វើការពេញនិយមសម្រាប់សិល្បករ ព្រោះវាជាមណ្ឌលទេសចរណ៍ផង និងជាមណ្ឌលសេដ្ឋកិច្ចផងនៃប្រទេសកម្ពុជា។ គួរឱ្យភ្ញាក់ផ្អើលដែរ មានសិល្បករពីរនាក់បានធ្វើការជាលក្ខណៈអន្តរជាតិ។




*រូប ២ : ភេទនៃសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌*




*រូប ៣ : ស្ថានភាពអាពាហ៍ពិពាហ៍របស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌*

*រូប ៤ : ទីតាំងដែលសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌រស់នៅ និងធ្វើការ*



## ការអប់រំ និងជំនាញវប្បធម៌

ភាគច្រើន សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ មិនចាំបាច់មានសញ្ញាបត្រកម្រិតសាកលវិទ្យាល័យ ដើម្បីអាចធ្វើការនៅក្នុងឧស្សាហកម្មវប្បធម៌ក្រៅប្រព័ន្ធនោះទេ។ ពួកគាត់ហាត់រៀនជំនាញទាំងនេះ តាមរយៈការបង្ហាត់បង្រៀនក្រៅប្រព័ន្ធពីមួយជំនាន់ទៅមួយជំនាន់។

សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ភាគច្រើន (៧៤.៤%) បានទទួល ឬបញ្ចប់ការអប់រំកម្រិតមូលដ្ឋាន (កម្រិតបឋមទៅកម្រិតអនុវិទ្យាល័យ) (រូប ៦)។ អ្នកធ្វើការក្នុងវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋភាគច្រើន បានទទួលការអប់រំរហូតដល់កម្រិតបឋមសិក្សា (២៨%) ហើយ ២៥.៤% បានបញ្ចប់កម្រិតអនុវិទ្យាល័យ។ សិល្បករក្នុងវិស័យឧស្សាហកម្ម វប្បធម៌ និងច្នៃប្រតិដ្ឋចំនួន ២១.៧% បានទទួល ឬ បញ្ចប់ការអប់រំកម្រិតវិទ្យាល័យ។ មានចំនួន ៥.៣% បានលើកឡើងថា ពួកគាត់ជាអនក្ខរជន (មិនអាចអាន មិនអាចសរសេរអក្សរ និងមិនចេះគិតលេខ) ហើយ ៥.១% បានទទួលការអប់រំក្រៅប្រព័ន្ធ (ដូចជារៀនអាន និងសរសេរ)។ មានសិល្បករចំនួនតិចតួចប៉ុណ្ណោះ ដែលបានទទួលការអប់រំកម្រិតសាកលវិទ្យាល័យ ដូចជាកម្រិតបរិញ្ញាប័ត្ររងចំនួន ២.៤% , កម្រិតបរិញ្ញាប័ត្រចំនួន ១០.១% និងកម្រិតអនុបណ្ឌិតចំនួន ១.៩%។ លទ្ធផលនេះបង្ហាញថា ការធ្វើការនៅក្នុងវិស័យឧស្សាហកម្មវប្បធម៌ ជាពិសេសផ្នែកតន្ត្រី និងសិល្បៈទស្សនីយភាព មិនចាំបាច់មានការអប់រំកម្រិតសាកលវិទ្យាល័យនោះទេ។ ដើម្បីក្លាយជាតន្ត្រីករ អ្នកចម្រៀង និងអ្នកសម្តែង អាចត្រូវការតែការបណ្តុះបណ្តាល និងការរៀនក្រៅប្រព័ន្ធ។ ៧៨.៣% បានរាយការណ៍ប្រាប់ថា ពួកគេបានរៀនដោយខ្លួនឯង ឬបង្រៀនដោយសាច់ញាតិ ឬឪពុកម្តាយ។ អ្នកផ្សេងទៀតចំនួន ២២.៧% ទទួលបានការបណ្តុះបណ្តាលជាផ្លូវការ (រូប ៥)។




*រូប ៥ : របៀបនៃការរៀនជំនាញរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌*




*រូប ៦ : កម្រិតការអប់រំរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌*

សិល្បករវប្បធម៌ក្រៅប្រព័ន្ធមានពហុជំនាញ។ សិល្បករច្រើនជាងពាក់កណ្ដាលបានចាត់ទុកជំនាញចម្បងរបស់ពួកគាត់ចូលក្នុងប្រភេទតន្ត្រី (៥១%) ដោយសារពួកគាត់ គឺជាអ្នកចម្រៀងសម័យ និងប្រពៃណី និងជាតន្ត្រីករ (រូប ៧)។ ប្រភេទតន្ត្រី ក៏ត្រូវបានចាត់ចំណាត់ថ្នាក់ថាជាជំនាញបន្ទាប់បន្សំរបស់សិល្បករ ជាពិសេសអ្នកដែលនៅក្នុងប្រភេទសិល្បៈទស្សនីយភាព សិប្បកម្ម និងសិល្បៈធ្វើម្ហូប ។ល។ ជំនាញដែលពេញនិយមបំផុតទីពីរ គឺសិល្បៈទស្សនីយភាព, សិល្បករចំនួនរហូតដល់ទៅ ២៣.៩១% បានចាត់ទុកខ្លួនឯងស្ថិតក្នុងក្នុងប្រភេទមួយនេះ និងមានសិល្បករប្រហែល ១១.៣% បានចាត់ទុកសិល្បៈទស្សនីយភាពថាជាជំនាញបន្ទាប់បន្សំរបស់ពួកគាត់។ សិប្បកម្ម និងសិល្បៈធ្វើម្ហូប (ចំពោះអ្នកធ្វើការផ្នែកឈើ, ដែក, ថ្ម, ចុងភៅ, អលង្ការ, តម្បាញ, កុលាលភាជន៍, សិល្បៈដាប់ស្បែក, ការចម្អិន, និងសកម្មភាពសិល្បៈធ្វើម្ហូបផ្សេងៗ) ត្រូវបានចាត់ថ្នាក់ទីបី ដែលមានចំនួន ១៥.៩% ហើយសិល្បករចំនួន ៤.៣% បានចាត់ទុកជំនាញនេះ ថាជាជំនាញចម្បង និងបន្ទាប់បន្សំរបស់ពួកគាត់រៀងៗខ្លួន។ ជំនាញទាំងបីប្រភេទដែលពេញនិយមនៅក្នុងវិស័យសិល្បៈវប្បធម៌ ទំនងជាត្រូវបាននាំមុខដោយទីផ្សារទេសចរណ៍ និងតម្រូវការកិច្ចពិធី និងប្រពៃណី។ ប្រភេទជំនាញនៅក្នុងវិស័យឧស្សាហកម្មវប្បធម៌ដែលមិនសូវមានការចាប់អារម្មណ៍ មានដូចជាសិល្បៈសូនរូប សោតទស្សន៍ អក្សរសិល្ប៍ និងការបោះពុម្ពផ្សាយ។

**សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ចេះជំនាញច្រើន ប៉ុន្តែជំនាញសិល្បៈទស្សនីយភាព និងតន្ត្រី គឺជាជំនាញចម្បង និងទីពីររបស់ពួកគាត់ ហើយពួកគាត់មានទំនោរចង់រៀនជំនាញតាមការបង្រៀនក្រៅប្រព័ន្ធ តែតម្លៃសិក្សាមិនថ្លៃពេក។**




*រូប ៧ : ជំនាញចម្បង និងជំនាញបន្ទាប់បន្សំរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌*

# សមាជិកភាព និងសម្ព័ន្ធភាព

សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ភាគច្រើន មិនមែនជាសមាជិករបស់សមាគម និងអង្គការមិនស្វែងរកប្រាក់ចំណេញណាមួយឡើយ សូម្បីតែស្ថាប័នរដ្ឋក៏ដោយ (៩៣%)។ ៧% បានឱ្យដឹងថា ពួកគាត់គឺជាសមាជិករបស់សមាគម (សិល្បករ ២៩ នាក់), ភាគច្រើនស្ថិតក្រោមចំណុះរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឬមន្ទីរវប្បធម៌តាមខេត្តរបស់ក្រសួង។ ចំនួនអ្នកចូលជាសមាជិករបស់អង្គការមាន ៦៨.៩០% ជាបុរស ហើយក្រៅពីនេះ ជាស្ត្រី។ សមាជិកភាព មានចំនួនសមាមាត្រត្រឹមត្រូវទៅនឹងយេនឌ័រនៃសិល្បករ ដែលមានបុរសច្រើនជាងស្ត្រី។

នៅពេលសួរពីមូលហេតុដែលពួកគាត់មិនចូលជាសមាជិក ឬសម្ព័ន្ធជាមួយអង្គការណាមួយនោះ មានចម្លើយជាច្រើនដែលយើងបានទទួល ប៉ុន្តែចម្លើយភាគច្រើនបង្ហាញថា ពួកគេមិនបានដឹងអំពីអង្គការសមាជិកភាពណាមួយឡើយ។ នៅក្នុងចំណោមពួកគាត់ អ្នកដែលមានសមាជិកភាព (អ្នកឆ្លើយ ២៩ នាក់) មាន ៤៥% ដែលធ្វើការនៅក្នុងប្រភេទតន្ត្រី, សោតទស្សន៍ (២១%) អក្សរសិល្ប៍ និងការបោះពុម្ពផ្សាយ (១៤%)។

> ពួកយើងមិនដឹងអំពីអង្គការសមាជិកភាពណាមួយ (ទោះជារដ្ឋាភិបាលក្តី និងមិនមែនរដ្ឋាភិបាលក្តី) ដែលពួកយើងគួរចូលរួមជាមួយ ដើម្បីឱ្យគេជាតំណាងពួកយើង និងអត្ថប្រយោជន៍របស់ពួកយើងនោះទេ។ គេតែងទាក់ទងពួកយើង តែតាមរយៈប្រធានក្រុមនៅក្នុងភូមិយើងប៉ុណ្ណោះ។




*រូប ៨ : ស្ថានភាពមាជិកភាពរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌*




*រូប ៩ : ប្រភេទនៃសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ជាមួយសមាជិកភាព*

# ការងារ និងលក្ខខណ្ឌការងារ

ភាគច្រើន សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ជាបុគ្គលស្វ័យនិយោជន៍ (៨៦%) ដោយពួកគាត់បានបញ្ជាក់ឱ្យដឹងថា ពួកគាត់គឺជាអ្នកធ្វើការឯករាជ្យ និងជាអ្នកសម្តែង អ្នកចម្រៀង អ្នកផ្តល់សេវាកម្ម និងផលិតករ/អ្នកបង្កើតឯករាជ្យ ហើយចំនួន ៤% ក្នុងចំណោមពួកគាត់បានចាត់ទុកខ្លួនថាជាសហគ្រិន ដែលមានអាជីវកម្មផ្ទាល់ខ្លួន ឬអាជីវកម្មលក្ខណៈគ្រួសារ (រូប ១០)។ សិល្បករទាំងនេះ ចាត់ទុកខ្លួនឯងថាជាអ្នកធ្វើការឯករាជ្យ ប៉ុន្តែនៅក្រោមសម្ព័ន្ធ ឬចំណុះរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ (៣%) និងមានចំនួនភាគរយដូចគ្នា បានចាត់ទុកខ្លួនឯងជាអ្នកធ្វើការដែលមានប្រាក់ខែ ប៉ុន្តែគ្មានកិច្ចសន្យាការងារ ដោយពួកគេធ្វើការឱ្យអាជីវកម្មខ្នាតតូចជាមួយប្រាក់ឈ្នួលប្រចាំ។ មានភាគរយតិចណាស់នៃចំនួនអ្នកធ្វើការក្នុងវិស័យឧស្សាហកម្មច្នៃប្រតិដ្ឋនិងវប្បធម៌ ដែលមានចុះកិច្ចសន្យាការងាររយៈពេលយូរ និងជាសិល្បករធ្វើការការងារក្រៅម៉ោង (១%) និងជាអ្នកស្ម័គ្រចិត្ត (២%)។

**ភាគច្រើន សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ជាបុគ្គលស្វ័យនិយោជន៍ និងធ្វើការខាងផ្នែកតន្ត្រី និងសិល្បៈទស្សនីយភាព។**




*រូប ១០ : លក្ខខណ្ឌការងារ និងការធ្វើការរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌*

ក្នុងចំណោម ៨៦% (៣៥៦ រូប) នៃសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ដែលជាបុគ្គលស្វ័យនិយោជន៍ មាន ៥០% ត្រូវបានចាត់នៅក្នុងប្រភេទតន្ត្រី និង ១៩% នៅក្នុងប្រភេទសិល្បៈទស្សនីយភាព។ ប្រភេទសិល្បៈធ្វើម្ហូប និងសិប្បកម្ម (៩%) ត្រូវបានចាត់នៅក្នុងប្រភេទបុគ្គលស្វ័យនិយោជន៍ដែលពេញនិយមបំផុតទីបី ហើយសិល្បៈសូនរូប និងសិល្បៈសោតទស្សន៍ស្ថិតនៅក្នុងចំណាត់ថ្នាក់ទីបួន (រូប ១១)។




*រូប ១១ : សិល្បករ និងអ្នកធ្វើការផ្នែកសិល្បៈ ជាមួយស្ថានភាពការងារស្វ័យនិយោជន៍*

ជាមធ្យម សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ក្រៅប្រព័ន្ធ មានបទពិសោធន៍ការងារយ៉ាងហោចណាស់ក៏ប្រាំមួយឆ្នាំដែរ។ អ្នកដែលនៅក្នុងប្រភេទតន្ត្រី មានបទពិសោធន៍យ៉ាងតិចណាស់ ១៩.១ ឆ្នាំ ខណៈអ្នកដែលនៅក្នុងប្រភេទសិល្បៈទស្សនីយភាព មានបទពិសោធន៍ជាមធ្យម ១៦.៥ ឆ្នាំ បន្ទាប់មកអ្នកនៅក្នុងប្រភេទសិល្បៈធ្វើម្ហូប និងសិប្បកម្ម (១៤.៥ ឆ្នាំ)។ សិល្បករដែលមានបទពិសោធន៍រយៈពេលយូរឆ្នាំជាងគេ គឺជាសិល្បករនៅក្នុងប្រភេទសិល្បៈធ្វើម្ហូប និងសិប្បកម្ម (៦០ ឆ្នាំ) ហើយបន្ទាប់មកប្រភេទតន្ត្រី (៥៨ ឆ្នាំ) និងសិល្បៈទស្សនីយភាព (៥៥ ឆ្នាំ)។ ទាំងនេះ បង្ហាញថា សិល្បករមួយចំនួនបានធ្វើការនៅក្នុងវិស័យនេះអស់រយៈពេលពេញមួយជីវិតរបស់ពួកគាត់។

**ជាមធ្យម សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ប្រភេទតន្ត្រី និងសិល្បៈទស្សនីយភាព មានបទពិសោធន៍ការងារយូរជាងគេនៅក្នុងវិស័យឧស្សាហកម្មនេះ។ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌មួយចំនួន បានធ្វើការនៅក្នុងវិស័យរបស់ខ្លួនរហូតដល់អាយុ ៨០ ឆ្នាំ។**




*រូប ១២ : ចំនួនឆ្នាំជាមធ្យមនៃបទពិសោធន៍ការងាររបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌*

ក្នុងរយៈកាលប្រាំមួយខែកន្លងទៅនេះ (ឆ្នាំ ២០២២) សិល្បករចំនួនប្រហែលជា ៧០% បាននិយាយថាពួកគេទទួលបានការងារធ្វើ ហើយ ៣០% ទៀតមិនមានការងារធ្វើ។ ក្នុងចំណោមសិល្បករ ចំនួន ៧០% ដែលមានការងារធ្វើ មាន ៥៩.១០% ជាបុរស និងប្រហែលជា ១០% ជាស្ត្រី។ នេះបង្ហាញឱ្យឃើញថា អត្រាគ្មានការងារធ្វើ (និកម្មភាព) ក្នុងអំឡុងពេលប្រាំមួយខែចុងក្រោយនៃឆ្នាំ២០២២ មានកម្រិតខ្ពស់ (ជិត ៣០%) ដោយភាគច្រើនជាបុរស ព្រោះថាចំនួនសិល្បករ និងអ្នកធ្វើការផ្នែកសិល្បៈភាគច្រើនជាបុរស (រូប ១៣)។ ដូច្នេះហើយ ពួកគាត់ប្រាកដជាចៀសមិនផុតពីការប្រឈមមុខនឹងបញ្ហាហិរញ្ញវត្ថុនៅក្នុងអំឡុងពេល ៦ ខែចុងក្រោយនោះទេ។

សម្រាប់អ្នកដែលមានការងារធ្វើក្នុងអំឡុង ៦ ខែចុងក្រោយនៃឆ្នាំ២០២២ នេះ ជាមធ្យម ពួកគេធ្វើការប្រហែលជាចំនួន ១៤.៥ ថ្ងៃក្នុងមួយខែ។ ខ្លះទៀតធ្វើការរហូតដល់ ៣០ ថ្ងៃក្នុងមួយខែ ហើយខ្លះធ្វើការប្រហែលតែ ១ ថ្ងៃ ក្នុង១ខែ។

សិល្បករទាំងអស់បាននិយាយថា ៩០%នៃពួកគាត់មានការងារធ្វើដោយពុំមានកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ ឬផ្លូវការឡើយ ខណៈ ១០% ទៀត (ប្រុស ៧%, ស្រី ៣%) បាននិយាយថា ពួកគាត់មានចុះកិច្ចសន្យា ឬកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរសម្រាប់ការផ្តល់សេវាកម្ម និងការងារ។ ដោយសារបុរសជាកម្លាំងពលកម្មចម្បងក្នុងវិស័យឧស្សាហកម្មវប្បធម៌ក្រៅប្រព័ន្ធ ដូចេ្នះគេអាចសន្និដ្ឋានថា អ្នកធ្វើការក្នុងវិស័យវប្បធម៌ដែលធ្វើការងារពុំមានចុះកិច្ចសន្យាត្រឹមត្រូវ ភាគច្រើនជាបុរស ។

**មានរហូតដល់ ៩០% នៃចំនួនសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ បានធ្វើការងារឱ្យអតិថិជនដោយពុំមានកិច្ចព្រមព្រៀង ឬកិច្ចសន្យាជាលាយលក្ខណ៍អក្សរ។**




*រូប ១៣ : ភាពមានការងារធ្វើ ក្នុងអំឡុងពេល ៦ ខែចុងក្រោយ គិតតាមភេទ*




*រូប ១៤ : លក្ខខណ្ឌការងារ និងលក្ខខណ្ឌនៃកិច្ចសន្យា*

សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ បានផ្តល់ចម្លើយខុសៗគ្នានៅពេលពួកយើងបានសួរអំពីអត្ថប្រយោជន៍នានា ដែលពួកគេបានទទួលក្រៅពីប្រាក់ឈ្នួលការងារ។ ៧៨.៧៤% នៃចំនួនសិល្បករបាននិយាយថា ពួកគេមិនដែលបានទទួលអត្ថប្រយោជន៍ណាមួយពីនិយោជក ឬអតិថិជនរបស់ពួកគេឡើយ។ នេះក៏អាចដោយសារការងារឯករាជ្យ និងសេវាកម្មដែលពួកគាត់ផ្តល់ជូនអតិថិជនស្ថិតនៅក្រៅប្រព័ន្ធ និងនៅពេលដែលពួកគាត់គ្មានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ។ ២១.២៦% (សិល្បករ ៨៨ នាក់) បានបញ្ជាក់ថា ពួកគាត់បានទទួលអត្ថប្រយោជន៍ជាច្រើនប្រភេទ ប៉ុន្តែមានអត្ថប្រយោជន៍តិចតួចប៉ុណ្ណោះដែលត្រូវបានចាត់ថ្នាក់ថាជាអត្ថប្រយោជន៍នៃប្រព័ន្ធគាំពារសង្គម ដូចជាការធានារ៉ាប់រងសុខភាព (៤.៥៥% = សិល្បករ ៤ នាក់), លំហែមាតុភាព (២.២៧% = សិល្បករ ២ នាក់), ការគាំពារសង្គមរបស់រដ្ឋ (២១.៥៩%=សិល្បករ ១៩ នាក់), ប័ណ្ណក្រីក្រ (១៨.១៨%=សិល្បករ ១៦ នាក់), ខណៈអ្នកផ្សេងទៀតបាននិយាយថាពួកគេបានទទួលប្រាក់ឧបត្ថម្ភ/ប្រាក់រង្វាន់ (៤៦.៥៩%=សិល្បករ ៤៦ នាក់) ហើយការបរិច្ចាគជាសប្បុរសធម៌ពីអតិថិជនរបស់ពួកគេ។ អ្នកដែលមានប័ណ្ណក្រីក្រ ចាត់ទុកជាសិល្បករក្រីក្រ ជាពិសេសអ្នកនៅតាមតំបន់ដាច់ស្រយាល។ អ្នកដែលមានប័ណ្ណគាំពារសង្គម (ប័ណ្ណសមាជិកប.ស.ស.) ឬប័ណ្ណសមធម៌ អាចជាសិល្បករស្ថិតក្រោមចំណុះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ហើយអ្នកដែលមានការធានារ៉ាប់រងសុខភាព គឺជាសិល្បករដែលមានចុះកិច្ចសន្យារយៈពេលយូរ។ លទ្ធផលនេះបង្ហាញថា គ្រួសារ និងសិល្បករក្រីក្រក៏មានតួនាទីសំខាន់នៅក្នុងវិស័យឧស្សាហកម្មវប្បធម៌ដែរ។

ភាគច្រើន សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ មិនដែលបានទទួលអត្ថប្រយោជន៍ណាមួយ ដូចជា ការធានារ៉ាប់រង និងការគាំពារសង្គមឡើយ ក្រៅតែពីប្រាក់ឈ្នួលសេវាដែលបានមកពី អតិថិជន ឬនិយោជិតរបស់ពួកគាត់។ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌មួយចំនួនមានជីវភាពក្រីក្រ។




*រូប ១៥ : អត្ថប្រយោជន៍ផ្សេងៗដែលសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ទទួលបាន*

ដោយសារសិល្បករភាគច្រើនជាអ្នកធ្វើការឯករាជ្យ ស្ទើរតែ៩០% នៃពួកគាត់ បាននិយាយថា ពួកគាត់មិនបានដឹងថាគេតម្រូវឱ្យពួកគាត់បង់ពន្ធលើប្រាក់ចំណូលដែលពួកគេរកបានពីការសម្ដែង ឬលក់ទំនិញនោះទេ។ យោងតាមភាពមិនទៀងទាត់ និងក្រៅផ្លូវការនៃសេវាកម្ម (ជាពិសេសការច្រៀង ការរាំ និងការសម្ដែងនៅតាមពិធី ឬកម្មវិធី) ពុំមានការដកពន្ធពីសិល្បករឡើយ ដោយរួមបញ្ចូលទាំងសិល្បករផ្នែកតន្ត្រី និងសិល្បៈទស្សនីយភាពផងដែរ។ (ចំណុចដែលត្រូវដឹងនោះ គឺថា ពុំមានទម្រង់បែបបទណាសម្រាប់ធ្វើការប្រកាសពន្ធខ្លួនឯងទេនៅកម្ពុជា)។ ពួកគេប្រហែលជា ១១.១០% បាននិយាយថា ពួកគេបានបង់ពន្ធលើប្រាក់ចំណូលរបស់ពួកគេ។ សិល្បករទាំងនេះ គឺជាអ្នកធ្វើការឯករាជ្យ ម្ចាស់អាជីវកម្ម និងអ្នកធ្វើការមានចុះកិច្ចសន្យារយៈពេលយូរ។ ការបង់ពន្ធ អាចត្រូវបានបង់ដោយនិយោជក ឬអតិថិជន ដែលបានកាត់ពន្ធទុក មុនពេលបង់ឱ្យសិល្បករ។

ស្ទើរតែ៩០% នៃចំនួនសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ទាំងអស់ មិនទាន់មានបទពិសោធន៍ជាមួយការដកពន្ធលើកម្រៃសេវាកម្មទេ។




*រូប ១៦ : ពន្ធលើប្រាក់ចំណូលដែលបានបង់ដោយ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌*

## ជីវភាពរស់នៅ

សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ត្រូវបានជួលឱ្យធ្វើការ និងសម្តែង ឬលក់ផលិតផលវប្បធម៌តាមរយៈបណ្តាញ និងមិត្តភក្តិ (៧៦.៤០%)។ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ចំនួន ១៥% បាននិយាយថា ពួកគាត់ត្រូវបានគេអញ្ជើញឱ្យសម្តែង និងផលិតស្នាដៃសិល្បៈ ដោយនរណាម្នាក់ ឬអង្គការបានទាក់ទងពួកគាត់ផ្ទាល់។ ខណៈពួកគេចំនួន ៥.១០% បាននិយាយថា ពួកគេបានលក់ផលិតផល និងទំនិញសិល្បៈ ទៅតាមទីផ្សាររួមបញ្ចូលទាំងការប្រូម៉ូសិន។ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ចំនួនតិចណាស់ បាននិយាយថា ពួកគេត្រូវបានគេជួលឱ្យធ្វើការតាមរយៈការប្រកួតប្រជែងដោយបើកចំហ (៣.៦០%)។

សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ទាំងអស់ ទំនងជាទទួលបានការងារតាមរយៈបណ្តាញ និងមិត្តភក្តិ។ បណ្តាញដើរតួនាទីយ៉ាងសំខាន់សម្រាប់ពួកគាត់។




*រូប ១៧ : របៀបដែលសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ទទួលបានការងារធ្វើ*

សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ភាគច្រើនបាននិយាយថា អាជីពចម្បងរបស់ពួកគាត់គឺ ឧស្សាហកម្មវប្បធម៌ ប៉ុន្តែវាគ្មានអ្វីដែលត្រូវភ្ញាក់ផ្អើលក្នុងការដឹងថា ២៥.១០% នៃប្រាក់ចំណូលរបស់ពួកគេបានមកក្រៅពីវិស័យវប្បធម៌។ លទ្ធផលនេះ អាចសម្រាប់អ្នកដែលរស់នៅតំបន់ដាច់ស្រយាល ដែលការងារវប្បធម៌របស់ពួកគេមានទៅតាមរដូវប៉ុណ្ណោះ ហើយជីវភាពរស់នៅរបស់ពួកគេ គឺពឹងផ្អែកលើរបរកសិកម្មតាមរដូវ។ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ចំនួន ៥០% បាននិយាយថា ប្រាក់ចំណូលចម្បងរបស់ពួកគាត់បានមកពីវិស័យវប្បធម៌ ខណៈដែល ២៤.៤០% បាននិយាយថា ចំណូលរបស់ពួកគាត់ បានមកពីវិស័យឧស្សាហកម្មវប្បធម៌ និងក្រៅវប្បធម៌ មានចំនួនដូចគ្នា។ លទ្ធផលនេះបង្ហាញថា យ៉ាងហោចណាស់ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ចំនួន ២៥.១០% មិនបានពឹងផ្អែកតែទៅលើការងារវប្បធម៌សម្រាប់ទ្រទ្រង់ជីវភាពរស់នៅទាំងស្រុងនោះទេ។

ឧស្សាហកម្មវប្បធម៌ មិនមែនជាប្រភពចំណូលតែមួយមុខសម្រាប់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់ឡើយ។ ដើម្បីទ្រទ្រង់ជីវភាពរស់នៅ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ធ្វើការនៅក្នុងវិស័យផ្សេងៗទៀត ជាពិសេសគឺប្រកបរបរកសិកម្ម។




*រូប ១៨ : ប្រភពចំណូលចម្បងរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌*

ដូចការបង្ហាញជូនខាងលើ មានសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ជាបុរស ច្រើនជាងស្ត្រី។ ទោះបីជាយ៉ាងណាក៏ដោយ ស្ត្រីទំនងជាគិតប្រាក់ឈ្នួលច្រើនជាងក្នុងមួយថ្ងៃ (អាចរហូតដល់$៤០ គឺ ប្រហែល$៥ ក្នុងមួយម៉ោង)[2] ធៀបនឹងបុរសដែលទទួលបាន $២៩ ក្នុងមួយថ្ងៃ (រូប ១៩)។ សិល្បករដែលមានអត្តសញ្ញាណភេទផ្សេងទៀត រកបាន ឬគិតប្រាក់ឈ្នួលលើសេវា $៥ ក្នុងមួយថ្ងៃជាមធ្យម។

**សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ជាស្ត្រី ទំនងជាគិតប្រាក់ឈ្នួលសេវាក្នុងមួយថ្ងៃថ្លៃជាងបុរស ប៉ុន្តែចំណូលរបស់ពួកគាត់មានទៅតាមរដូវកាល ហើយស្ត្រីទំនងជាឆាប់បោះបង់អាជីពរបស់ខ្លួនលឿនជាងបុរស ។ អ្នកខ្លះបាននិយាយថា «ប្រាក់ឈ្នួលសេវាការងារមិនគ្រប់នឹងការចំណាយក្នុងធ្វើការងារនោះផង»។**




*រូប ១៩ : ប្រាក់ឈ្នួលសេវាដែលរកបានក្នុងមួយថ្ងៃ គិតតាមភេទ*

ការស្ទង់មតិបង្ហាញថា ចំណូល[3]ប្រចាំឆ្នាំជាមធ្យមរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ បានធ្លាក់ចុះយ៉ាងគំហុកពីឆ្នាំ ២០១៩ ($១,៩១៤) ទៅឆ្នាំ ២០២០ ($១,១៨៨) ប៉ុន្តែវាក៏បានកើនឡើងបន្តិចម្តងៗពី $១,៣២០ ក្នុងឆ្នាំ ២០២១ ទៅ $១,៤៦៨ ក្នុងឆ្នាំ ២០២២ (រូប ២០)។ ការធ្លាក់ចុះប្រាក់ចំណូល និងការកើនឡើងដ៏យឺត គឺអាស្រ័យលើបម្រែបម្រួលសេដ្ឋកិច្ច ដែលបង្កដោយជំងឺរាតត្បាត។ ក្នុងឆ្នាំ ២០១៩ ចំណូលដែលរកបានដោយសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌មានកម្រិតលើផលិតផលក្នុងស្រុកសរុប (GDP) របស់កម្ពុជាតែបន្តិច

---

2 ក្រុមការងារពួកយើងបានសង្កេតឃើញថា សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ជាស្ត្រីរកប្រាក់ និងគិតប្រាក់ឈ្នួលបានតិចជាងបុរស។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលអាចបង្ហាញឱ្យឃើញថា សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ជាស្ត្រី ដែលគិតប្រាក់ឈ្នួលបានថ្លៃជាងបុរស (ជាពិសេសប្រធានក្រុម) អាចបណ្តាលឱ្យប្រាក់ឈ្នួលជាមធ្យម ដែលពួកគេមានកម្រិតខ្ពស់ជាង ក្នុងខណៈចំនួនសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ជាស្ត្រី ដែលបានឆ្លើយកម្រងសំណួរ មានតិចជាងបុរស។

3 ចំណូលនេះ យោងទៅតាមចំណូលសរុប ដែលពួកគេរកបាន ជាជាងចំណូលសុទ្ធ (បន្ទាប់ពីចំណាយរួច)។

ប៉ុណ្ណោះក្នុងម្នាក់ ($១,៦៧១)[4] នៅក្នុងឆ្នាំដដែល។ ប្រាក់រកបានគិតជាមធ្យមក្នុងឆ្នាំ ២០២១ ពិតជាទាបជាង GDP ជាមធ្យម ក្នុងឆ្នាំ ២០២០ ($១,៥៧៧)។ ខណៈ GDP របស់កម្ពុជាជាមធ្យមរើបឡើងដល់ $១,៦២៥ ក្នុងឆ្នាំ ២០២១ ចំណូលរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌នៅតែទាប។ ការកើនឡើងដ៏យឺតនេះអាចមកពីការកើនឡើងយឺតនៃចំនួនទេសចរក្នុងស្រុក និងអន្តរជាតិ និងការរើបឡើងយ៉ាងយឺតនៃសេដ្ឋកិច្ចក្នុងស្រុក។ ដោយមិនរាប់បញ្ចូលពីការផ្លាស់ប្តូរនៅក្នុងប្រាក់ចំណូលប្រចាំឆ្នាំរបស់ពួកគេ ចំណូលរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ក្នុងមួយឆ្នាំបានបង្ហាញថា ពួកគេគឺជាអ្នកចូលរួមចំណែកក្នុងសេដ្ឋកិច្ចរបស់ប្រទេសដ៏សកម្ម។

ចរន្តនៃប្រាក់ចំណូលប្រចាំឆ្នាំ ដែលរកបានដោយសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ម្នាក់ៗ មានការធ្លាក់ចុះយ៉ាងខ្លាំងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ហើយលទ្ធភាពនៃការរើបឡើងវិញមានល្បឿនយឺតដោយសារមូលហេតុច្រើនយ៉ាង។ ដោយពុំគិតពីការប្រែប្រួលប្រាក់ចំណូលរបស់ពួកគាត់ក៏ដោយ ក៏ចំណូលប្រចាំឆ្នាំរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យសិល្បៈ បង្ហាញឱ្យឃើញថា ពួកគាត់ចូលរួមចំណែកយ៉ាងសកម្មនៅក្នុងសេដ្ឋកិច្ច។




*រូប ២០ : ចរន្តនៃប្រាក់ចំណូលប៉ាន់ស្មានប្រចាំឆ្នាំ របស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ពីឆ្នាំ ២០១៩ ដល់ ២០២២*

ខណៈចំណូលរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ អាចប្រៀបធៀបនឹងផលិតផលក្នុងស្រុកសរុប (GDP) ក្នុងមនុស្សម្នាក់នោះ ចំណូលដែលសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ក្រៅប្រព័ន្ធរកបានក៏មានភាពមិនដូចគ្នា។ ផ្នែកសិល្បៈទស្សនីយភាពរកបានតិចជាងគេបំផុត ($១,១២៥ ក្នុងឆ្នាំ ២០១៩, $២៥៩ ក្នុងឆ្នាំ ២០២០) ធៀបនឹងផ្នែកតន្ត្រី (រកបាន $១,៦៧៦ ក្នុងឆ្នាំ ២០១៩, $៧១៣ ក្នុងឆ្នាំ ២០២០) ជាអ្នករកចំណូលបានតិចជាងគេបំផុតទីពីរ និងផ្នែកសិល្បៈសូនរូប ដែលជាអ្នករកចំណូលតិចជាងគេបំផុតទីបី (រូប ២១)។ សិល្បករ និងអ្នកធ្វើការក្នុងប្រភេទផ្សេងៗនៃវិស័យវប្បធម៌ (ការលក់ទំនិញនិងការផលិតភាពយន្ត) ព្រមទាំង សិប្បកម្មនិងសិល្បៈធ្វើម្ហូប បានចាត់នៅក្នុងប្រភេទអ្នករកចំណូលបានច្រើនជាងគេបំផុត ក្នុងវិស័យឧស្សាហកម្មវប្បធម៌។ ក្នុងឆ្នាំ ២០១៩ អ្នកដែលនៅក្នុងប្រភេទផ្សេងទៀតរកចំណូលបានរហូតដល់ $៤,៨៥០ ខណៈដែលសិប្បកម្ម និងសិល្បៈធ្វើម្ហូបរកបានតែ $៣,០០០ ក្នុងមួយឆ្នាំ។ នៅក្នុងចរន្តដូចគ្នា អ្នកធ្វើការទាំងអស់គ្រប់ផ្នែកនៃឧស្សាហកម្មវប្បធម៌ មានការធ្លាក់ចុះប្រាក់ចំណូលយ៉ាងខ្លាំងក្នុងឆ្នាំ ២០២០។ ទោះបីមានការរីកចម្រើនបន្តិចម្តងៗពីឆ្នាំ២០២១ ទៅ ២០២២ ចំណូលរបស់ពួកគេមិនទាន់បានរើបឡើងវិញនៅឡើយទេ បើធៀបទៅនឹងពេលដែលមិនទាន់មានជំងឺកូវីដក្នុងឆ្នាំ ២០១៩។

---

[4] ប្រព័ន្ធទិន្នន័យធនាគារពិភពលោក ។ បានយកនៅថ្ងៃទី ១៥ កុម្ភៈ ២០២៣ ពី: https://data.worldbank.org/indicator/NY.GDP.PCAP.CD?end=2021&locations=KH&start=2015




*រូប ២១ : ចរន្តនៃចំណូលប្រចាំឆ្នាំជាមធ្យម ដែលរកបានដោយសិល្បករ និងអ្នកធ្វើការក្នុងវិស័យ ឧស្សាហកម្មវប្បធម៌*

សិល្បករ និងអ្នកធ្វើការផ្នែកតន្ត្រី និងផ្នែកសិល្បៈទស្សនីយភាព រកបានចំណូលប្រចាំឆ្នាំតិចជាងគេបំផុត ធៀបនឹងផ្នែកដទៃទៀត។ ចំណូលប្រចាំឆ្នាំជាមធ្យមរបស់ពួកគាត់ ពិតជាទាបជាងផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់។

ចំណូលរបស់វិស័យឧស្សាហកម្មវប្បធម៌ មានភាពផ្សេងៗគ្នា ទៅតាមលក្ខខណការងារ និងការរកចំណូលរបស់ពួកគាត់។ អ្នកដែលធ្វើការងារឯករាជ្យ និងចំណុះឱ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រកបានចំណូលតិចជាងគេបំផុត ($៣៣០-$៥៨៦) ខណៈសិល្បករស្វ័យនិយោជន៍ រកបានចំណូលតិចជាងគេបំផុតទីពីរ គឺរវាង $៩៥៣ ទៅ $១,៨១៤ ក្នុងមួយឆ្នាំ។ អ្នកដែលស្ថិតក្នុងប្រភេទអាជីវកម្មលក្ខណៈគ្រួសារ ឬសហគ្រិន ទំនងជារកបានច្រើនជាង រហូតដល់ $៦,៥៨៦ ក្នុងមួយឆ្នាំ។ សិល្បករដែលមានចុះកិច្ចសន្យាការងាររយៈពេលយូរ អាចរកចំណូលបានរហូតដល់ $១០,០០០ ក្នុងមួយឆ្នាំ (រូប ២២)។




*រូប ២២ : ចំណូលដែលរកបានដោយសិល្បករក្នុងលក្ខខណ្ឌការងារគ្រប់ប្រភេទក្នុងវិស័យវប្បធម៌*

ដោយមិនគិតពីសកម្មភាពរកចំណូល និងលក្ខខណ្ឌការងាររបស់ពួកគាត់ ៤៥.៨%នៃចំនួនសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ (ភាគច្រើនជាបុរស) ជាប់បំណុល ដោយសារពួកគាត់បានខ្ចីប្រាក់ពីប្រភពផ្សេងៗ ដូចជាអ្នករកស៊ីចងការប្រាក់ សាច់ញាតិ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារ (រូប ២៣)។ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ផ្សេងទៀត បាននិយាយថា ពួកគេមិនមានជាប់បំណុលទេ។ ខណៈពេលសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ស្ទើរតែពាក់កណ្ដាលជាប់បំណុល សិល្បករចំនួន ៨០.៦០% (៥៨.៧០% ជាបុរស) បាននិយាយថា ពួកគេមិនមានការសន្សំប្រាក់ជាសាច់ប្រាក់ឬជាគណនីធនាគារទេ។ ១៩.៤០% បាននិយាយថា ពួកគេមានការសន្សំជាសាច់ប្រាក់ ឬជាគណនីធនាគារ។

**ស្ទើរតែ ៥០% នៃចំនួនសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ មានជាប់បំណុល។ យ៉ាងហោចណាស់ ក៏មាន ៨០% នៃចំនួនសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ គ្មានប្រាក់សន្សំទេ មិនថាជាសាច់ប្រាក់សុទ្ធ ឬជាគណនីធនាគារ។**




*រូប ២៣ : ស្ថានភាពជាប់បំណុលរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌*




*រូប ២៤ : សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ដែលមាន និងគ្មានការសន្សំ*

# ផលប៉ះពាល់នៃជម្ងឺរាតត្បាត

យ៉ាងហោចណាស់ក៏មានសិល្បករ និងអ្នកធ្វើការនៅក្នុងវិស័យវប្បធម៌ចំនួន ៨០% ដែរ ដែលបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីជំងឺរាតត្បាត។ អ្នកដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ គឺអ្នកនៅផ្នែកតន្ត្រី និងសិល្បៈទស្សនីយភាព ដូច្នេះ ពួកគាត់បានក្លាយជាជនងាយរងគ្រោះបំផុតនៅក្នុងវិស័យឧស្សាហកម្មវប្បធម៌ក្រៅប្រព័ន្ធ។

ភាពស៊ីគ្នាទៅនឹងចរន្តធ្លាក់ចុះនៃការរកចំណូលពីឆ្នាំ២០១៩ ទៅ ២០២២ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ បានទទួលរងផលប៉ះពាល់ជាអវិជ្ជមានពីជំងឺរាតត្បាត (កូវីដ១៩)។ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ចំនួន៨៤.២៤% (ក្នុងនោះមាន ៥៩% ជាបុរស) បានទទួលរងផលប៉ះពាល់ពីជំងឺរាតត្បាត រីឯសិល្បករនិងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ចំនួន ១០.២៤% បាននិយាយថា ពួកគាត់ទទួលរងផលប៉ះពាល់កម្រិតតូច និង ៦% និយាយថារងផលប៉ះពាល់មធ្យម (រូប ២៥)។ ក្នុងចំណោមសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ដែលបានទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីជំងឺរាតត្បាត ពួកគេចំនួន ៤៧% នៅក្នុងផ្នែកតន្ត្រី, ២២% ក្នុងផ្នែកសិល្បៈទស្សនីយភាព ហើយ ១០% ក្នុងផ្នែកសិប្បកម្ម និងសិល្បៈធ្វើម្ហូប (រូប ២៦)។ នេះបង្ហាញថា អ្នកដែលរកបានតិចជាងគេ (សិល្បករ និងអ្នកធ្វើការផ្នែកសិល្បៈទស្សនីយភាព និងតន្ត្រី) ទំនងជាអ្នករងគ្រោះជាងគេ ដោយសារជីវភាពរស់នៅរបស់ពួកគាត់ទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីជំងឺរាតត្បាត។ ស្របពេលជាមួយគ្នានេះ អ្នកដែលរកប្រាក់បានច្រើនជាងគេ (សោតទស្សន៍, សិប្បកម្ម និងសិល្បៈធ្វើម្ហូប, និងសិល្បៈសូនរូប) ទំនងជាទទួលរងផលប៉ះពាល់តិចជាងគេពីជំងឺរាតត្បាត។




*រូប ២៥ : កម្រិតដែលជំងឺរាតត្បាតធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ និងការប្រកបការងារ*

អ្នកដែលរកប្រាក់ចំណូលប្រចាំឆ្នាំបានតិចជាងគេ ជាពិសេសអ្នកនៅខាងផ្នែកសិល្បៈទស្សនីយភាព និងតន្ត្រី ទំនងជារងផលប៉ះពាល់ធ្ងន់ធ្ងរពីវិបត្តិសេដ្ឋកិច្ចដែលបណ្តាលមកពីជំងឺរាតត្បាត។ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ងាយនឹង រងគ្រោះខ្លាំងពីការប្រែប្រួលអវិជ្ជមានខ្លាំងនៃសេដ្ឋកិច្ច។




*រូប ២៦ : ការជះផលអវិជ្ជមានជាច្រើនពីជំងឺរាតត្បាតតាមទម្រង់នីមួយៗនៃវិស័យវប្បធម៌*

សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ជាច្រើនរូប (៨៨.៨០%) បាននិយាយថា ពួកគាត់មិនបានទទួលជំនួយគាំទ្រណាមួយសម្រាប់ជីវភាពរស់នៅរបស់ពួកគាត់ឡើយ ជាពិសេសអំឡុងពេលបិទខ្ទប់ (រូប ២៧)។ ប្រហែល ១០% បាននិយាយថា ពួកគាត់បានទទួលជំនួយគាំទ្រអំឡុងពេលបិទខ្ទប់ពីក្រុមប្រឹក្សាឃុំ/សង្កាត់ និងកម្មវិធីរដ្ឋាភិបាលរួមមានប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារក្រីក្រ។ អ្នកដែលមានប័ណ្ណក្រីក្រ ទទួលបានប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាល។ ជំនួយគាំទ្ររួមមាន អង្ករ ម្ហូប ប្រាក់ និងរបស់របរផ្សេងៗ។ អ្នកដែលមិនបានទទួលជំនួយគាំទ្រពីរដ្ឋាភិបាល បានទៅរកជំនួយពីមិត្តភក្តិ និងសាច់ញាតិជាប្រាក់ និងរបស់របរផ្សេងៗ ដើម្បីទ្រទ្រង់ជីវភាពក្នុងពេលបិទខ្ទប់ ដែលជាពេលមានការរឹតត្បិតរាល់ការជួបជុំ រួមមានការជួបជុំសម្រាប់ការសម្តែង និងការច្រៀងផងដែរ។




*រូប ២៧ : ជំនួយគាំទ្រពីភាគីផ្សេងៗ អំឡុងពេលបិទខ្ទប់*

## ភាពប្រឈម និងសេចក្តីរំពឹងទុក

ការប្រែប្រួលជាខ្លាំងពីសេដ្ឋកិច្ច និងបច្ចេកវិទ្យាឌីជីថលនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ បានជះឥទ្ធិពលដល់ជីវភាពរស់នៅរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យឧស្សាហកម្មវប្បធម៌ក្រៅប្រព័ន្ធ។ នៅពេលយើងបានសួរអំពីការប្រឹងប្រែងនៅពេលអនាគត រួមមានដំណើរ និងការអភិវឌ្ឍអាជីព សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ភាគច្រើន (៧២%) បាននិយាយថា ពួកគាត់នឹងមិនផ្លាស់ប្តូរអាជីពរបស់ពួកគេចេញពីវិស័យឧស្សាហកម្មវប្បធម៌ឡើយ ទោះបីជាមានសិល្បករចំនួន ២២% ចង់ផ្លាស់ប្តូរមុខរបររបស់ពួកគេ (រូប ២៨)។ បំណងផ្លាស់ប្តូរនេះ កើតឡើងដោយសារការគ្មានលទ្ធភាពទ្រទ្រង់ជីវភាពរស់នៅ ដោយសារការងារ និងប្រាក់ចំណូលក្នុងវិស័យឧស្សាហកម្មក្រៅប្រព័ន្ធមិនមានភាពទៀងទាត់។ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ផ្សេងទៀត មិនច្បាស់ថាតើពួកគេគួរចាប់យកអាជីពផ្សេងទៀត ឬអត់នោះទេ។

យ៉ាងហោចណាស់ មានសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ចំនួន ២២% ទំនងជាផ្លាស់ប្តូរអាជីពរបស់ពួកគាត់ទៅធ្វើការក្នុងវិស័យផ្សេង ដើម្បីទ្រទ្រង់ជីវភាពឱ្យកាន់តែល្អប្រសើរ។

ដោយសារបច្ចេកវិទ្យាឌីជីថល ជាចំណែកដ៏សំខាន់នៅក្នុងការងារសិល្បៈ និងទំនាក់ទំនង សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ចំនួន ៤៥.៦៤% បានសម្តែងឱ្យឃើញថា ពួកគាត់ចង់រៀនជំនាញបច្ចេកវិទ្យាឌីជីថលដើម្បីអភិវឌ្ឍអាជីពរបស់ពួកគេក្នុងវិស័យឧស្សាហកម្មវប្បធម៌ (រូប ២៩)។ អ្នកដែលមានបំណងចង់រៀនជំនាញបច្ចេកវិទ្យាឌីជីថល ទំនងជាសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ស្ថិតក្រោមអាយុ ៤០ ឆ្នាំ។ ខណៈដែល ៣៩.១២% បាននិយាយថា ពួកគាត់មិនចង់រៀនជំនាញបច្ចេកវិទ្យាឌីជីថល និងមានសិល្បករចំនួន ១៤.៧៤% បាននិយាយថា ពួកគាត់មិនច្បាស់ថាតើការរៀនជំនាញបច្ចេកវិទ្យាឌីជីថលនឹងជួយដល់អាជីពរបស់ពួកគាត់នៅពេលអនាគតយ៉ាងដូចម្តេចឡើយ។ អ្នកដែលមិនចង់រៀនបាននិយាយថា ពួកគាត់ចាស់ពេកហើយ ឬពួកគាត់មិនឃើញពីប្រយោជន៍ដែលជំនាញបច្ចេកវិទ្យាឌីជីថលអាចជួយដល់ការហាត់សិល្បៈ និងការសម្តែងរបស់ពួកគេនោះទេ ជាពិសេសអ្នកនៅផ្នែកសិល្បៈទស្សនីយភាព និងតន្ត្រី។

ស្ទើរតែពាក់កណ្តាលនៃសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ដែលឆ្លើយតបនឹងគម្រោងស្រាវជ្រាវបង្ហាញថា ពួកគាត់ចង់រៀនជំនាញប្រព័ន្ធផ្សព្វផ្សាយឌីជីថល និងជំនាញបច្ចេកវិទ្យាសម្រាប់កសាងបណ្តាញ និងពង្រឹងអាជីពនាពេលអនាគតក្នុងវិស័យឧស្សាហកម្មវប្បធម៌។




*រូប ២៨ : ការយល់ដឹងរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ជុំវិញថាតើពួកគាត់គួរផ្លាស់ប្តូរអាជីព ឬក៏អត់*




*រូប ២៩ : បំណងរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ដែលចង់រៀនជំនាញបច្ចេកវិទ្យាឌីជីថល ដើម្បីពង្រឹងអាជីព*

**ការធ្វើការនៅក្នុងវិស័យឧស្សាហកម្ម មានន័យថា «អភិរក្សគុណតម្លៃវប្បធម៌ និងប្រពៃណី» ដែលមិនអាចកាត់ថ្លៃបាន ប៉ុន្តែការតាំងចិត្តបែបនោះ មិនទទួលបាន ការផ្តល់តម្លៃ ឬការទទួលស្គាល់ តាមរយៈការផ្តល់ជំនួយហិរញ្ញវត្ថុឬ ជំនួយផ្សេងៗ និងការលើកទឹកចិត្តឡើយ។**

ការវិភាគទិន្នន័យបង្ហាញថា សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ភាគច្រើន គឺជាអ្នកនៅផ្នែកសិល្បៈទស្សនីយភាព និងតន្ត្រី រួមមានសិល្បៈទស្សនីយភាព និងតន្ត្រីសម័យបុរាណ។ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ទាំងនេះ រកបានប្រាក់ចំណូលតិចជាងគេបំផុត ដោយសារតែតម្រូវការទីផ្សារផ្នែកនីមួយៗមានតាមរដូវកាលប៉ុណ្ណោះ។ អ្នកខ្លះបាននិយាយថា “ពួកយើងមិនអាចរស់បាន ដោយសារការសម្តែង និងច្រៀងឡើយ ប៉ុន្តែពួកយើងស្រលាញ់ និងត្រូវការអភិរក្សប្រពៃណីនិងវប្បធម៌ខ្មែរយើង”។ គុណតម្លៃ និងតម្លៃនៃវប្បធម៌មានតម្លៃជាងចំណូលដែលពួកគេរកបាន។ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ខ្លះបាននិយាយថា “ប្រាក់កម្រៃដែលម្ចាស់កម្មវិធីឱ្យ តិចជាការចំណាយលើការរៀបចំសម្តែងទៅទៀត ប៉ុន្តែពួកយើងព្រមទទួលយកការងារ គឺដើម្បីអភិរក្សវប្បធម៌ដែលមានតម្លៃមិនអាចកាត់ថ្លៃបាន”។ ខណៈការងារនេះត្រូវបានចាត់ទុកថាជាការលះបង់របស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ក៏មានមនុស្ស និងស្ថាប័នពាក់ព័ន្ធជាច្រើនមិនឱ្យតម្លៃដល់ការខំប្រឹងប្រែងនេះ។ ពុំមានការទទួលស្គាល់ និងឱ្យតម្លៃ ដូចជាការផ្តល់ប្រាក់ឧបត្ថម្ភ ឬការគោរពជាដើម ទៅដល់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ឡើយ រួមទាំងសិល្បករមានពិការភាពផង។ សិល្បករទាំងនេះ បាននិយាយថា “គ្មានរង្វាន់លើកទឹកចិត្ត ដូចជាការជួយផ្នែកហិរញ្ញវត្ថុ និងសម្ភារ ដើម្បីផ្តល់ជូនសិល្បករឱ្យបន្តការងារក្នុងវិស័យវប្បធម៌ឡើយ”។

**សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ បាននិយាយថា ពួកគេចង់ចាកចេញពីវិស័យឧស្សាហកម្មវប្បធម៌ ពីព្រោះ “គ្មានរង្វាន់លើកទឹកចិត្ត ដូចជាការជួយជាប្រាក់ និងសម្ភារ ផ្តល់ជូនដល់ពួកគេ ដើម្បីបន្តការងារនៅក្នុងវិស័យនេះទេ”។**

ទោះបីជាមានការប្តេជ្ញាអភិរក្សតម្លៃវប្បធម៌ខ្មែរ និងការចូលរួមចំណែកក្នុងវិស័យសេដ្ឋកិច្ច (ដូចជាការជួយទាក់ទាញភ្ញៀវទេសចរណ៍, ការជួយបង្កើតការងារ, រួមចំណែក និងងការធ្វើពិធីបុណ្យក្នុងសហគមន៍ និងពិធីបុណ្យធំៗ, រួមចំណែករកចំណូលគ្រួសារ, គាំទ្រសកម្មភាពផ្សេងៗ ។ល។) សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ទាំងអស់ ទាំងអ្នករកបានចំណូលតិច និងច្រើន មិនដែលមានជំនួយប៉ះប៉ូវ ឬជំនួយគាំពារដោយការធានារ៉ាប់រងសង្គម ឬដោយស្ថាប័នពាក់ព័ន្ធណាមួយឡើយ។ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ផ្នែកសិល្បៈទស្សនីយភាព និងតន្ត្រី មានជីវភាពក្រីក្រ ហើយក្នុងនោះ មានអ្នកខ្លះក៏ទទួលបានការផ្តល់ជូនប័ណ្ណក្រីក្រពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់រដ្ឋាភិបាល។ សិល្បករនិងអ្នកធ្វើការក្នុងវិស័យវប្បធម៌ទាំងនេះ មិនមានការផ្តល់ជូននូវគម្រោងគាំពារសង្គមរបស់រដ្ឋ ដែលអាចជួយឱ្យទទួលបានការគាំពារសុខភាពសាធារណៈឥតគិតថ្លៃឡើយ។

សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ភាគច្រើនរស់នៅគ្រប់កន្លែងទូទាំងប្រទេសកម្ពុជា ប៉ុន្តែផ្តល់សេវាកម្មនៅក្នុងខេត្តដែលមានសកម្មភាពសេដ្ឋកិច្ចចម្បង ដូចជា ភ្នំពេញ សៀមរាប បាត់ដំបង កំពង់ធំ និងកំពត។ ខណៈសិល្បករនិងអ្នកធ្វើការក្នុងវិស័យវប្បធម៌ភាគច្រើនមានទំនាក់ទំនងនឹងសារព័ត៌មានសង្គមតាមរយៈទូរស័ព្ទដៃវៃឆ្លាតរបស់ពួកគេក៏ដោយ ក៏មានតែប្រធានក្រុមម្នាក់ប៉ុណ្ណោះ ដែលជាអ្នកទទួលការងារសម្តែង។ ពុំមានវេទិកាកណ្តាលណាមួយ ដែលអាចជួយឱ្យសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ជាបុគ្គលម្នាក់ៗ ដើម្បីទាក់ទងក៏ដូចជាទៅរកបណ្តាញនៅទូទាំងប្រទេសនិងខេត្តឡើយ។ ដូចដែលបានបង្ហាញនៅក្នុងការស្ទង់មតិ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ភាគច្រើន មិនដឹងអំពីបណ្តាញក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធដើម្បីជួយសម្របសម្រួលឱ្យពួកគេអាចទទួលបានដំណឹង ព័ត៌មាន និងធនធាន ដែលទាក់ទងនឹងជំនាញវប្បធម៌។ ដូចគ្នានេះដែរ សំណើរបស់ពួកគេដូចជាការស្វែងរកកន្លែងដើម្បីបណ្តុះអ្នកជំនាន់ក្រោយ និងដើម្បីសមការសម្តែងរបស់ពួកគេ មិនត្រូវបានគេដឹង ឬទទួលស្គាល់ដោយស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលឡើយ។

បញ្ហាយេនឌ័រនៅក្នុងឧស្សាហកម្មវប្បធម៌ គឺជារឿងសំខាន់មួយ បើយោងតាមទំនាក់ទំនងរបស់ក្រុមស្រាវជ្រាវជាមួយនឹងសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌។ ការសិក្សានេះបានរកឃើញថា សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ភាគច្រើនជាបុរស ព្រោះស្ត្រីបន្ទាប់ពីរៀបការរួច ប្តីឬសាច់ញាតិមិនអនុញ្ញាតឱ្យបន្តអាជីពទៀតឡើយ។ សិល្បករជាបុរសមួយចំនួនបានអះអាងថា “អាជីពជាអ្នកសម្តែង និងជាអ្នកចម្រៀងរបស់ពួកគេនឹងបញ្ចប់នៅពេលពួកគេរៀបការ មានគភ៌ និងនៅពេលមើលថៃកូន”។

> “អាជីពជាអ្នកសម្តែង និងជាអ្នកចម្រៀងរបស់ពួកគេនឹងបញ្ចប់ នៅពេលពួកគេរៀបការ មានគភ៌ និងនៅពេលមើលថៃកូន” ។

## សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

ការសិក្សានេះបានឈ្វេងយល់អំពីធនធានវប្បធម៌ក្រៅប្រព័ន្ធរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ដោយកំណត់អំពីស្ថានភាពប្រជាសាស្ត្រ ការអប់រំ និងជំនាញ ស្ថានភាពនៃជីវភាពរស់នៅ និងភាពប្រឈម និងដំណើរអាជីពរបស់ពួកគេ ។ ការស្ទង់មតិជាមួយសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ចំនួន ៤១៤ នាក់ បានបង្ហាញថា ខណៈពេលដែលស្ត្រី ត្រូវបានគេដឹងជាទូទៅថាមានតួនាទីសំខាន់ក្នុងការអភិរក្សវប្បធម៌នៅក្នុងប្រទេស បែរជាសិល្បករនិងអ្នកធ្វើការក្នុងវិស័យឧស្សាហកម្មវប្បធម៌ភាគច្រើនជាបុរសទៅវិញ។ បញ្ហានេះ អាចដោយសារស្ត្រីទំនងចូលប្រឡូកការងារក្នុងវិស័យឧស្សាហកម្មក្រៅប្រព័ន្ធនៅអាយុក្មេង ហើយចាកចេញពីអាជីពរបស់ខ្លួនឆាប់ជាងបុរស ជាពិសេសនៅពេលពួកគេរៀបការ និងមានភារកិច្ចមើលថែកូន និងអាចដោយសារជំនាញដែលសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ជាស្ត្រីមានកម្រិត។

សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ក្រៅប្រព័ន្ធ ចេះជំនាញក្នុងវិស័យវប្បធម៌ច្រើន ប៉ុន្តែជំនាញដែលបានរៀនចម្បងគឺតន្ត្រី និងសិល្បៈទស្សនីយភាព ដែលជាប្រភេទសិល្បៈដែលលេចធ្លោជាងគេនៅក្នុងវិស័យវប្បធម៌។ ខណៈដែលសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ មានកម្រិតអប់រំខុសៗគ្នា អ្នកនៅក្នុងប្រភេទសិល្បៈទស្សនីយភាព និងតន្ត្រី មានកម្រិតអប់រំចន្លោះពីបឋមសិក្សា និងអនុវិទ្យាល័យ។ រីឯអ្នកដទៃដែលនៅក្នុងប្រភេទសោតទស្សន៍, សិប្បកម្ម និងសិល្បៈធ្វើម្ហូប, និងសិល្បៈសូនរូប ទំនងជាទទួលបានកម្រិតអប់រំខ្ពស់ជាង។ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ផ្នែកតន្ត្រី និងសិល្បៈទស្សនីយភាព បានរៀនជំនាញនៅក្នុងវិស័យរបស់ខ្លួនពីការបណ្តុះបណ្តាលក្រៅប្រព័ន្ធ ដូចជារៀនពីឪពុកម្តាយ សាច់ញាតិ និងមិត្តភក្តិ នៅក្នុងសហគមន៍ច្រើនជាងការរៀននៅសាលាជាផ្លូវការ។

សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ស្ទើរតែទាំងអស់ មិនបានដឹងអំពីអង្គការសមាជិកភាពណាមួយដែលពួកគេគួរតែចូលរួមនោះទេ។ ទំនាក់ទំនង និងបណ្តាញរបស់ពួកគេ មានលក្ខណៈក្រៅផ្លូវការ ដោយទាក់ទងតាមរយៈប្រធានក្រុម/សហគមន៍នៅក្នុងសហគមន៍នីមួយៗ ខណៈដែលការទំនាក់ទំនងរវាងផ្នែកសិល្បៈផ្សេងៗក្នុងវិស័យឧស្សាហកម្មវប្បធម៌ទូទាំងប្រទេសនៅមានកម្រិតនៅឡើយ ទោះបីជាសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ស្ទើរតែទាំងអស់បានប្រើ ឬមានទូរស័ព្ទវៃឆ្លាតដែលអាចភ្ជាប់ជាមួយអ៊ិនធឺណិតបានក៏ដោយ។ ភាពមានកម្រិតនេះ បានធ្វើឱ្យសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ មានការពិបាកក្នុងការស្វែងរកព័ត៌មាន ក៏ដូចជាពិបាកក្នុងការផ្សព្វផ្សាយទៅកាន់វិស័យឧស្សាហកម្មវប្បធម៌ដែលមានទំហំកាន់តែធំជាងនេះ នៅក្នុងប្រទេសនិងតំបន់អាស៊ីអាគ្នេយ៍ ដោយធ្វើឱ្យឱកាសអភិវឌ្ឍនិងរីកចម្រើននៅក្នុងអាជីពរបស់ពួកគេមានកម្រិតផងដែរ។

សកម្មភាពរកចំណូលរបស់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ក្រៅប្រព័ន្ធ មានភាពខុសៗគ្នា ប៉ុន្តែជាចម្បងស្ថិតនៅក្នុងប្រភេទ “ការងារឯករាជ្យ” ឬ“ស្វ័យនិយោជន៍”។ ពួកគាត់មួយចំនួនតូចគឺជាម្ចាស់អាជីវកម្មលក្ខណៈគ្រួសារ និងសហគ្រាសខ្នាតតូច។ សិប្បកម្មនិងសិល្បៈធ្វើម្ហូប សោតទស្សន៍ និងសិល្បៈសូនរូប ទំនងជារកចំណូលបានច្រើនជាង ដែលធ្វើឱ្យពួកគេទទួលរងគ្រោះតិចជាងចំពោះការប្រែប្រួលសេដ្ឋកិច្ចដោយសារជំងឺរាតត្បាត។ អ្នកនៅក្នុងប្រភេទស្វ័យនិយោជន៍ ភាគច្រើនគឺជាអ្នកនៅផ្នែកសិល្បៈទស្សនីយភាព និងតន្ត្រី ទំនងជារកចំណូលបានតិចជាងគេ បើធៀបទៅនឹងប្រភេទ ឬផ្នែកដទៃទៀត ដូចជាផ្នែកសិល្បៈសូនរូប សោតទស្សន៍ សិប្បកម្ម និងសិល្បៈធ្វើម្ហូប។ បើលាយបញ្ចូលគ្នារវាងកម្រិតទាបបំផុតនៃចំណូលដែលពួកគេរកបានតាមរដូវកាល និងកម្រិតទាបនៃការអប់រំ សិល្បករ និងអ្នកធ្វើការផ្នែកតន្ត្រី និងសិល្បៈទស្សនីយភាព ទំនងជាទទួលរងគ្រោះជាងនៅក្នុងការប្រែប្រួលសេដ្ឋកិច្ចដោយសារជំងឺរាតត្បាត និងដោយសារការលូតលាស់សេដ្ឋកិច្ចយឺត។ ជំងឺរាតត្បាត បានជះឥទ្ធិពលអវិជ្ជមានលើសិល្បករ និងអ្នកធ្វើការផ្នែកតន្ត្រី និងសិល្បៈទស្សនីយភាពយ៉ាងធ្ងន់ធ្ងរបើធៀបនឹងផ្នែកសិល្បៈសូនរូប សោតទស្សន៍ និងសិប្បកម្ម និងសិល្បៈធ្វើម្ហូប។ ដោយមិនគិតអំពីការប្រែប្រួលចំណូលប្រចាំឆ្នាំដោយសារ

ការប្រែប្រួលសេដ្ឋកិច្ចនិងជំងឺរាតត្បាត សិល្បករ និងអ្នកធ្វើការក្នុងវិស័យឧស្សាហកម្មវប្បធម៌ក្រៅប្រព័ន្ធ គឺជាចំនួនប្រជាជនសេដ្ឋកិច្ចសកម្មដែលបានចូលរួមចំណែកយ៉ាងសំខាន់ទៅនឹងសេដ្ឋកិច្ច ដោយផ្អែកលើចំណូលប្រចាំឆ្នាំរបស់ពួកគេ មានអ្នកខ្លះមានប្រាក់ចំណូលលើសពីផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ (GDP per capita) ទៀតផង។ សកម្មភាពរបស់ពួកគេបានចូលរួមចំណែក និងចូលរួមជួយដល់សេដ្ឋកិច្ចរបស់ប្រទេសដោយប្រយោល។

សិល្បករ និងអ្នកធ្វើការផ្នែកតន្ត្រី និងសិល្បៈទស្សនីយភាពភាគច្រើន បានលើកឡើងថា ប្រាក់កម្រៃដែលពួកគេរកបានមិនគ្រប់គ្រាន់ទេ ដូច្នេះហើយពួកគេត្រូវពឹងផ្អែកទៅលើមុខរបរផ្សេងទៀត ដើម្បីទ្រទ្រង់ជីវភាពរស់នៅ។ ទោះបីជាយ៉ាងណាក៏ដោយ សិល្បករនិងអ្នកធ្វើការក្នុងវិស័យវប្បធម៌ទាំងនេះ នៅតែបន្តធ្វើការនៅក្នុងវិស័យនេះ ដោយធ្វើការប្តេជ្ញាអភិរក្សតម្លៃវប្បធម៌និងប្រពៃណីរបស់ប្រទេសដែលមិនអាចយកប្រាក់ឈ្នួលដែលអតិថិជនឱ្យមកប៉ះប៉ូវបានឡើយ។ ពួកគេក៏បានលើកឡើងទៀតថា អ្នកពាក់ព័ន្ធ មិនដែលទទួលស្គាល់ឬឱ្យតម្លៃដល់ការប្តេជ្ញារបស់ពួកគេជាហិរញ្ញវត្ថុឬសម្ភារឡើយ។ សិល្បករនិងអ្នកធ្វើការក្នុងវិស័យវប្បធម៌ភាគច្រើន បាននិយាយថា ពួកគាត់មិនបានទទួលប្រយោជន៍ពីគម្រោងគាំពារសង្គម ដូចជាការផ្តល់ប័ណ្ណក្រីក្រ ដោយកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នោះទេ។ សិល្បករនិងអ្នកធ្វើការក្នុងវិស័យវប្បធម៌ភាគច្រើន បាននិយាយថា ពួកគាត់មិនបានទទួលជំនួយគាំទ្រពីរដ្ឋាភិបាលឡើយ។ អំឡុងពេលបិទខ្ទប់ដោយសារតែការរាតត្បាតនៃជំងឺកូវីដ១៩ ពួកគាត់មិនបានទទួលជំនួយឧបត្ថម្ភអ្វីឡើយ។

ទោះបីជាពួកគេជួបប្រទះនឹងការលំបាកនានាខាងផ្នែកហិរញ្ញវត្ថុ និងផ្នែកសម្ភារក្តី សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ជាច្រើន បាននិយាយថា ពួកគាត់មិនបោះបង់អាជីព និងចំណាប់អារម្មណ៍របស់ពួកគេក្នុងវិស័យនេះឡើយ ខណៈពួកគេមួយចំនួនតូចគិតចង់ប្តូរអាជីពរបស់ខ្លួនទៅវិស័យផ្សេងទៀត។ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ប្រហែលជា ៥០% ចង់រៀនជំនាញបច្ចេកវិទ្យាឌីជីថល ដើម្បីពង្រឹងអាជីព និងសេវាកម្មការងាររបស់ខ្លួន ខណៈអ្នកផ្សេងទៀត ជាពិសេសសិល្បករ និងអ្នកធ្វើការដែលមានវ័យចំណាស់ជាងនេះ មិនមើលឃើញពីអត្ថប្រយោជន៍នៅក្នុងជំនាញបច្ចេកវិទ្យាឌីជីថលនោះទេ។

តាមរយៈទិន្នន័យដែលបានរកឃើញ គម្រោងស្រាវជ្រាវនេះ សូមបង្ហាញ និងផ្តល់អនុសាសន៍ទៅដល់ភាគីពាក់ព័ន្ធនូវចំណុចមួយចំនួនដូចខាងក្រោម ៖

- ការស្ទង់មតិបានរកឃើញថា សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ បានរួមចំណែកក្នុងសេដ្ឋកិច្ចកម្ពុជា តាមរយៈលទ្ធភាពនៃការរកចំណូលទ្រទ្រង់សម្រាប់មនុស្សម្នាក់ៗ។ ទោះបីជាយ៉ាងណាក៏ដោយ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ទាំងនេះ មិនទទួលបានជំនួយគាំទ្រដោយគម្រោងគាំពារសង្គម ដូចជា ប័ណ្ណសមធម៌និងប័ណ្ណក្រីក្រ នោះទេ ទោះបីជាពួកគាត់បានខិតខំប្រឹងប្រែងថែរក្សា និងអភិរក្សប្រពៃណី និងវប្បធម៌ដែលមិនអាចកាត់ថ្លៃបាននេះក៏ដោយ។ គួរតែមានគម្រោងគាំពារសង្គម និងធានារ៉ាប់រងសម្រាប់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ជាពិសេសអ្នកដែលធ្វើការខាងផ្នែកតន្ត្រី និងសិល្បៈទស្សនីយភាព ដែលតែងតែធ្វើដំណើរទៅសម្តែងនៅតាមកន្លែងផ្សេងៗឆ្ងាយពីសហគមន៍របស់ខ្លួន។
- ការថែរក្សាវប្បធម៌ដែលមិនអាចកាត់ថ្លៃបានរបស់កម្ពុជា ទាមទារឱ្យមានរង្វាន់លើកទឹកចិត្តជាហិរញ្ញវត្ថុ និងសម្ភារ ដើម្បីជួយដល់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ក្នុងការអភិរក្សវប្បធម៌ និងបង្រៀនបន្តនូវបទពិសោធន៍ និងជំនាញពាក់ព័ន្ធរបស់ពួកគាត់ក្នុងវិស័យឧស្សាហកម្មវប្បធម៌ ទៅឱ្យក្មេងជំនាន់ក្រោយក្នុងសហគមន៍ ស្រុក និងខេត្តរបស់ពួកគាត់។ អ្នកពាក់ព័ន្ធដែលជាស្ថាប័នរដ្ឋក្តី និងមិនមែនរដ្ឋក្តី គួរផ្តល់

រង្វាន់លើកទឹកចិត្ត ដូចជាកម្មវិធីផ្តល់មូលនិធិ និងបណ្តុះបណ្តាល ដើម្បីជួយគាំទ្រក្រុមសិល្បករ អ្នកធ្វើការក្នុងវិស័យវប្បធម៌ និងអ្នកដែលចង់ចាប់យកអាជីពក្នុងឧស្សាហកម្មវប្បធម៌។

- សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ខ្វះមធ្យោបាយទទួលបានព័ត៌មាន និងឱកាសផ្សេងៗ ព្រោះពួកគាត់រស់ និងធ្វើការនៅទីកន្លែងផ្សេងៗគ្នា ដោយសារពុំមានអ្នកតំណាងសមរម្យ។ ដោយការទាក់ទងជាមួយសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ត្រូវធ្វើឡើងតាមរយៈប្រធានក្រុមក្នុងភូមិ ឃុំ និងស្រុកនីមួយៗ ហើយប្រធានក្រុមខ្លួនឯងពុំមានទំនាក់ទំនងទូលំទូលាយជាមួយស្ថាប័នរដ្ឋ និងមិនមែនរដ្ឋដើម្បីជួយគាំទ្រសកម្មភាពរបស់ពួកគាត់។
- មានតម្រូវការដើម្បីបង្កើតវេទិកាដែលឱ្យសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ទាំងអស់អាចធ្វើទំនាក់ទំនងចែករំលែកព័ត៌មាន និងធនធាន ព្រមទាំងស្វែងរកឱកាសផ្សេងៗ ដែលទាក់ទងនឹងសកម្មភាពឧស្សាហកម្ម វប្បធម៌ និងច្នៃប្រតិដ្ឋ។ គួរតែមានការចែករំលែកព័ត៌មានជាប្រចាំនៅលើវេទិកាមួយដែលសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌មកពីគ្រប់ជំនាញ និងតំបន់អាចទទួលបាន។ វេទិកានឹងអនុញ្ញាតឱ្យសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌បញ្ចេញគំនិតយោបល់របស់ពួកគាត់ និងចែករំលែកព័ត៌មានដែលសំខាន់សម្រាប់អាជីពការងារ និងជីវភាពរស់នៅរបស់ពួកគាត់។
- ចំពោះអ្នកពាក់ព័ន្ធទាំងអស់ ជាពិសេស ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ជាការចាំបាច់ណាស់ក្នុងការផ្តល់សិទ្ធិអំណាច និងតម្លៃដល់ការចូលរួមរបស់ស្ត្រីនៅក្នុងឧស្សាហកម្ម វប្បធម៌ និងច្នៃប្រតិដ្ឋ ដើម្បីជួយទ្រទ្រង់ និងរក្សាតួនាទីរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ចច្នៃប្រតិដ្ឋ និងវប្បធម៌ក្រៅប្រព័ន្ធ។ ការងារនេះ អាចធ្វើទៅបានតាមរយៈការជួយគាំទ្រស្មារតី និងការលើកទឹកចិត្តពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងពីសហគមន៍។
- បច្ចេកវិទ្យាឌីជីថល មានឥទ្ធិពលលើគ្រប់ទិដ្ឋភាពនៃសេដ្ឋកិច្ច និងវប្បធម៌របស់កម្ពុជា ។ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ អាចប្រើប្រព័ន្ធអ៊ិនធឺណិតប្រើ និងទទួលបានព័ត៌មានសង្គម ប៉ុន្តែសមត្ថភាពសិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ភាគច្រើនមានកម្រិតក្នុងការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីជាប្រយោជន៍ដល់អាជីពរបស់ពួកគាត់។ យ៉ាងហោចណាស់ក៏មានសិល្បករចំនួន ៤៥% ចាប់អារម្មណ៍រៀនអំពីប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកវិទ្យាឌីជីថល ដើម្បីអភិវឌ្ឍអាជីពរបស់ពួកគាត់។

# ឯកសារយោង

Lubart, T. I. (2001). Models of the creative process: Past, present and future. Creativity research journal, 13(3-4), 295-308; Botella, M., Zenasni, F., & Lubart, T. (2018). What are the stages of the creative process? What visual art students are saying. Frontiers in psychology, 2266.

Skovronska, I (2021). Creative industries and the informal sector: Ukrain's experience. UNCTAD. Accessed 02 Feb 2022: https://unctad.org/system/files/non-official-document/DITC2020_Contribution_UNCTAD%20Illicit%20Trade%20Forum_Skavronska_en.pdf

Smith, J.D (1985): Market motives in the informal economy, in: Gaertner, W. and Wenig, A. (eds.): The economics of the informal economy, Heidelberg: Springer Publishing Company, pp. 161-177.

UNESCO (2001). UNESCO Universal Declaration on Cultural Diversity. Paris: UNESCO.

UNESCO (2021). Cultural and creative industries in the face of COVID-19: an economic impact outlook. UNESCO. Accessed 02 Feb 2022: https://unesdoc.unesco.org/ark:/48223/pf0000377863

UNESCO & World Bank. (2021). Cities, Culture, Creativity: Leveraging Culture and Creativity for Sustainable Urban Development and Inclusive Growth. UNESCO and World Bank: Washington DC



With the support of

unesco

Diversity of
Cultural Expressions

ស៊ីកាដា
cicada

សម្រាប់ពតិ៌មានបន្ថែម សូមចូលមើលគេហទំព័រ៖
www.cicadakh.org